លោក ឌិន ឈាន

# វេយ្យាករណ៍ខ្មែរ

# Khmer Grammar

## សំរាប់អ្នកសិក្សាទូទៅ




រក្សាសិទ្ធិ

ព.ស. ២៥៤៦ គ.ស. ២០០២

3

PB...2012.........

495-9325
ឈាង
ក្ប-3

# វេយ្យាករណ៍ខ្មែរ

ថ្មី ! ថ្មី ! សន្ទាង
## សំរាប់អ្នកសិក្សាទូទៅ

អ្វីៗដែលអ្នកចង់ដឹង អំពីវេយ្យាករណ៍ខ្មែរ

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

00023512

រក្សាសិទ្ធិ

បោះពុម្ពលើកទី ១ ចំនួន៤០០០ច្បាប់

លោក ឆន ឈាង

ព.ស.២៥៤៥ — គ.ស.២០០២

## សេចក្ដីឧទ្ទិស

ខ្ញុំសូមឧទ្ទិសស្នាដៃនេះ ជូនចំពោះវិញ្ញាណក្ខន្ធលោកឪពុកហ៊ិន ឆន, លោកតា រស់ មៅក, លោកយាយ ឥន្ទ សុខ, និងលោកយាយ ក្លិន ព្រមទាំងញាតិសន្ដានទាំងអស់ ដែលបានធ្វើមរណកាលទៅកាន់លោកខាងមុខរួចហើយ ។

## កតញ្ញូតាគថា

ខ្ញុំសូមវន្ទាចំពោះគុណ អ្នកបានធ្វើមុនមកលើខ្ញុំ
ដូចជាអ្នកម្ដាយដ៏ឧត្ដម រួមផ្សំបងប្អូនក្រុមគ្រួសារ ។
ព្រមទាំងលោកគ្រូនិងអ្នកគ្រូ វិញ្ញូជនមានសាស្ត្រាចារ្យ
ដែលបានបង្រៀនផ្ដល់បញ្ញា អក្ខរានពួន្ដដល់រូបខ្ញុំ ។
ខ្ញុំសូមប្រសិទ្ធនូវពរជ័យ សិរីសួស្ដីថ្លៃឧត្ដម
ព្រោះអ្នកមានគុណជាបឋម ពូអ៊ីបងប្អូនទាំងអស់គ្នា ។

ខ្ញុំបាទ ឆន ឈាន

# អារម្ភកថា

សៀវភៅ **វេយ្យាករណ៍ខ្មែរ** ដែលលោកអ្នកកំពុងកាន់នៅក្នុងដៃនេះ គឺប្រសូត្រឡើងក្នុងគោលបំណងឆ្លើយតបទៅនឹង សេចក្ដីត្រូវការចង់យល់ដឹងរបស់លោកអ្នក ដែលជាអ្នកសិក្សាភាសាខ្មែរ ដើម្បីយកទៅធ្វើការស្រាវជ្រាវ ពិភាក្សាលើការងាររបស់ខ្លួន ។

សៀវភៅ **វេយ្យាករណ៍ខ្មែរ**នេះ មុននឹងកើតឡើង ខ្ញុំបានចំណាយពេលយ៉ាងយូរ ក្នុងការស្រាវជ្រាវរាវរក ឯកសារភាសាខ្មែរនិងភាសាបរទេស ដើម្បីយកមកផ្ទឹមផ្ទៀងត្រិះរិះពិចារណា ធ្វើយ៉ាងណារកអោយឃើញនូវភាពច្បាស់លាស់នៃក្បួនច្បាប់វេយ្យាករណ៍ខ្មែរយើង ។ ប៉ុន្តែជាការពិតឯកសារមួយចំនួន ទាំងភាសាខ្មែរនិងភាសាបរទេស ដែលខ្ញុំយកមកធ្វើការសិក្សាប្រៀបផ្ទឹមនោះ មានចំណុចខ្លះហាក់បីដូចជាពុំមានការឯកភាពគ្នាសោះ ។ ហេតុនេះធ្វើអោយខ្ញុំមានការពិបាកក្នុងការសម្រេចចិត្តថាតើ មួយណាត្រឹមត្រូវនិងមួយណាពុំសូវត្រឹមត្រូវ តែទោះជាយ៉ាងណាក៏ដោយខ្ញុំត្រូវតែប្រកាន់យក ឯកសារភាគច្រើនដែលមានការឯកភាពនឹងគ្នា និងជាឯកសារស្នាដៃនៃអ្នកនិពន្ធល្បីៗផង ។ ដូច្នេះសៀវភៅនេះពិតជានៅមានការខ្វះខាត ចំណុចណាមួយចៀសមិនផុតឡើយ ។

ខ្ញុំសង្ឃឹមជឿជាក់ថាសៀវភៅនេះ នឹងផ្ដល់ផលប្រយោជន៍ក្នុងកំរិតណាមួយដល់អ្នកសិក្សាជាក់ជាមិនខាន ។ យើងខ្ញុំរង់ចាំទទួលការទិតៀនស្ថាបនា រាល់កំហុសឆ្គងជាអចេតនា ពីលោកអ្នកដោយរីករាយ ៕

***ចេះវេយ្យាករណ៍ខ្មែរយើងច្បាស់លាស់ ជួយ ឱ្យលោកអ្នករៀនភាសាបរទេសងាយ។***

សូមលោកអ្នកទទួលបានជោគជ័យក្នុងការសិក្សា!

# ឯកសារពិគ្រោះ


| ឈ្មោះឯកសារ | ឈ្មោះអ្នកនិពន្ធ |
| --- | --- |
| ***I. ឯកសារភាសាខ្មែរ*** | |
| ១. វចនានុក្រមខ្មែរ | សម្ដេចសង្ឃរាជ **ជួន ណាត** |
| ២. វចនានុក្រមខ្មែរ | លោក **នួន ប៊ុត** |
| ៣. សៀវភៅអក្សរផ្ចង់ | លោក **នួន ប៊ុត** |
| ៤. វេយ្យាករណ៍ខ្មែរ | លោក **ពួច អ៊ុំ** |
| ៥. មូលភាពនៃការបង្កើតពាក្យថ្មី | លោក **កេង វ៉ាន់សាក់** |
| ៦. វេយ្យាករណ៍ថ្នាក់ទី៥ ដល់ទី៨ | កម្មការនិពន្ធក្រសួងអប់រំ |
| ៧. សៀវភៅកំនាព្យភាគ១-២ | លោក **លី សុមុនី** |
| ៨. វចនានុក្រមខ្មែរអង់គ្លេស | Robertj K.Headley,.. |
| ៩. ភាសាខ្មែរ | លោក **អៀង កើស** |
| ១០. បរិវាសព្ទ | **ស៊ីសុវត្ថិ ប៉ូរក្ខស៊ី** |
| ***II. ឯកសារភាសាបរទេស*** | |
| 1. OXFORD Dictionary | A S Hornby |
| 2. English-khmer Dictionary | Visal,Sopha,Vannak |
| 3. ENGLISH GRAMMAR | Betty Schrampfer Azar |
| 4. The Writer's Handbook | Elizabeth McMahan |
| 5. The Writer's Craft | Sheridan Blau |
| 6. Oxford Practice Grammar | John Eastwood |
| 7 English Syntax | Roderick A. jacobs |

*រួមជាមួយឯកសារផ្សេងៗទៀតជាច្រើនផងដែរ ។*

# បញ្ជីអត្ថបទ


| ល.រ | ឈ្មោះអត្ថបទ | ទំព័រ |
|---|---|---|
| ១. | អក្សរខ្មែរ | ០១ |
| ២. | ពាក្យ | ០៧ |
| ៣. | ថ្នាក់ពាក្យ | ២៨ |
| ៤. | អំពីនាម | ២៩ |
| ៥. | អំពីសព្វនាម | ៣៧ |
| ៦. | អំពីកិរិយាសព្ទ | ៤២ |
| ៧. | អំពីគុណនាម | ៥០ |
| ៨. | អំពីគុណកិរិយា | ៥៦ |
| ៩. | អំពីធ្នាក់ | ៦៤ |
| ១០. | អំពី ឈ្នាប់ | ៦៧ |
| ១១. | អំពី ឧទានសព្ទ | ៦៩ |
| ១២. | អំពីល្បះ | ៧១ |
| ១៣. | អំពីកន្សោមពាក្យ | ៨០ |
| ១៤. | អំពីប្រភេទឃ្លា | ៨១ |
| ១៥. | អក្សរជ្រៀង | ៨៥ |
| ១៦. | អក្សរឈរ | ៨៦ |
| ១៧. | អក្សរខម | ៨៧ |
| ១៨, | អក្សរមូល | ៨៨ |
| ១៩. | អក្សរក្បាច់ | ៨៩ |
| ២០. | អំពីគំនូសតាងល្បះ | ៩១ |

# អក្សរខ្មែរ

Khmer Alphabet

**អក្សរ** (Alphabet) គឺជាស្នាមគំនូស មានទ្រង់ទ្រាយផ្សេងៗគ្នា អាស្រ័យលើជាតិសាសន៍នីមួយៗ ដែលគេបានបង្កើតឡើង ។ គេបង្កើតវាឡើងដើម្បីកត់ត្រាពាក្យសំដី ,ចងក្រងក្បួនច្បាប់ហោរាសាស្ត្រ ,ផ្តល់ព័ត៌មានពីកន្លែងមួយទៅកន្លែងមួយទៀត ,កត់ត្រាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ,ចងក្រងក្បួនច្បាប់សាសនា ,កត់ត្រារូបមន្តវិទ្យាសាស្ត្រ ។ល។ អក្សររួមមាន: *ព្យញ្ជនៈ ,ស្រៈ លេខ* និង*វណ្ណយុត្តិ* ថែមទៀតផង ។

ចំពោះអក្សរខ្មែរយើងមានរូបរាងពិសេសប្លែក ពីអក្សរជាតិសាសន៍ដទៃគឺ:

- ចំពោះព្យញ្ជនៈមាន៖ តួខ្លួន ,សក់ និងជើង ។
- ចំពោះស្រៈមាន៖ ដាក់ពីមុខព្យញ្ជនៈផង និងពីក្រោយព្យញ្ជនៈផង ហើយនិង ពីលើព្យញ្ជនៈផង និងពីក្រោមព្យញ្ជនៈផង ។
- ចំពោះលេខមាន៖លក្ខណៈស្រដៀងនឹងព្យញ្ជនៈដែរតែគ្មានជើងទេ ។
- ចំណែកវណ្ណយុត្តិវិញមាន៖ ដាក់នៅពីមុខ ,ពីក្រោយ ,និងពីលើពាក្យ ប៉ុន្តែពុំមានឃើញដាក់ពីក្រោមទេ ។

**១.ព្យញ្ជនៈ** (Consonan) គឺជាតួអក្សរនីមួយៗសម្រាប់ផ្សំជាមួយនឹងស្រៈ ,លុះត្រាតែមានស្រៈផ្សំផង ទើបអាចបង្កើតជាពាក្យសម្តីបាន ។ ព្យញ្ជនៈក្នុងភាសាខ្មែរយើងរួមមាន ៣៣ តួ បូកនឹងព្យញ្ជនៈបន្ថែម

# បញ្ជីអត្ថបទ


| ល.រ | ឈ្មោះអត្ថបទ | ទំព័រ |
|---|---|---|
| ១. | អក្សរខ្មែរ | ០១ |
| ២. | ពាក្យ | ០៧ |
| ៣. | ថ្នាក់ពាក្យ | ២៨ |
| ៤. | អំពីនាម | ២៩ |
| ៥. | អំពីសព្វនាម | ៣៧ |
| ៦. | អំពីកិរិយាសព្ទ | ៤២ |
| ៧. | អំពីគុណនាម | ៥០ |
| ៨. | អំពីគុណកិរិយា | ៥៦ |
| ៩. | អំពីធ្នាក់ | ៦៤ |
| ១០. | អំពី ឈ្នាប់ | ៦៧ |
| ១១. | អំពី ឧទានសព្ទ | ៦៩ |
| ១២. | អំពីល្បះ | ៧១ |
| ១៣. | អំពីកន្សោមពាក្យ | ៨០ |
| ១៤. | អំពីប្រភេទឃ្លា | ៨១ |
| ១៥. | អក្សរជ្រៀង | ៨៥ |
| ១៦. | អក្សរឈរ | ៨៦ |
| ១៧. | អក្សរខម | ៨៧ |
| ១៨, | អក្សរមូល | ៨៨ |
| ១៩. | អក្សរក្បាច់ | ៨៩ |
| ២០. | អំពីគំនូសតាងល្បះ | ៩១ |

# អក្សរខ្មែរ

Khmer Alphabet

**អក្សរ** (Alphabet) គឺជាស្នាមគំនូស មានទ្រង់ទ្រាយផ្សេងៗគ្នា អាស្រ័យលើជាតិសាសន៍នីមួយៗ ដែលគេបានបង្កើតឡើង ។ គេបង្កើតវាឡើងដើម្បីកត់ត្រាពាក្យសំដី ,ចងក្រងក្បួនច្បាប់ហោរាសាស្ត្រ ,ផ្តល់ព័ត៌មានពីកន្លែងមួយទៅកន្លែងមួយទៀត ,កត់ត្រាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ,ចងក្រងក្បួនច្បាប់សាសនា ,កត់ត្រារូបមន្តវិទ្យាសាស្ត្រ ។ល។ អក្សររួមមាន: *ព្យញ្ជនៈ ,ស្រៈ លេខ* និង*វណ្ណយុត្តិ* ថែមទៀតផង ។

ចំពោះអក្សរខ្មែរយើងមានរូបរាងពិសេសប្លែក ពីអក្សរជាតិសាសន៍ដទៃគឺ:

- ចំពោះព្យញ្ជនៈមាន៖ តួខ្លួន ,សក់ និងជើង ។

- ចំពោះស្រៈមាន៖ ដាក់ពីមុខព្យញ្ជនៈផង និងពីក្រោយព្យញ្ជនៈផង ហើយនិង ពីលើព្យញ្ជនៈផង និងពីក្រោមព្យញ្ជនៈផង ។

- ចំពោះលេខមាន៖លក្ខណៈស្រដៀងនឹងព្យញ្ជនៈដែរតែគ្មានជើងទេ ។

- ចំណែកវណ្ណយុត្តិវិញមាន៖ ដាក់នៅពីមុខ ,ពីក្រោយ ,និងពីលើពាក្យ ប៉ុន្តែពុំមានឃើញដាក់ពីក្រោមទេ ។

**១.ព្យញ្ជនៈ** (Consonan) គឺជាតួអក្សរនីមួយៗសម្រាប់ផ្សំជាមួយនឹងស្រៈ ,លុះត្រាតែមានស្រៈផ្សំផង ទើបអាចបង្កើតជាពាក្យសម្តីបាន ។ ព្យញ្ជនៈក្នុងភាសាខ្មែរយើងរួមមាន ៣៣តួ បូកនឹងព្យញ្ជនៈបន្ថែម

១១តួទៀតត្រូវជា៤៤តួគឺ៖

**ក្ក ខ្ខ គ្គ ឃ្ឃ ង្ង    ច្ច ឆ្ឆ ជ្ជ ឈ្ឈ ញ្ញ[1]**

**ដ្ដ ឋ្ឋ ឌ្ឌ ឍ្ឍ ណ្ណ    ត្ត ថ្ថ ទ្ទ ធ្ធ ន្ន**

**ប្ប ផ្ផ ព្ព ភ្ភ ម្ម    យ្យ រ្រ ល្ល វ្វ ស្ស ហ្ហ ឡ្ឡ អ្អ**

ក្ក ខ្ខ គ្គ ឃ្ឃ ង្ង  ច្ច ឆ្ឆ ជ្ជ ឈ្ឈ ញ្ញ  ដ្ដ ឋ្ឋ ឌ្ឌ ឍ្ឍ ណ្ណ

ត្ត ថ្ថ ទ្ទ ធ្ធ ន្ន  ប្ប ផ្ផ ព្ព ភ្ភ ម្ម  យ្យ រ្រ ល្ល វ្វ ស្ស ហ្ហ ឡ្ឡ អ្អ

*ព្យញ្ជនៈបន្ថែម៖ ង៉ ញ៉ ប៉ ម៉ យ៉ រ៉ វ៉ ប៊ ស៊ ហ៊ អ៊*

ព្យញ្ជនៈភាគច្រើនអាចជាព្យញ្ជនៈប្រកប តែមានមួយចំនួនតូចមិនអាចយកប្រើធ្វើជាព្យញ្ជនៈប្រកបបានទេ ។ ព្យញ្ជនៈទាំងនេះមានដូចខាងក្រោម៖

| | | |
|---|---|---|
| ក : សុក , រក | ខ : សុខ , | គ : សំយោគ |
| ឃ : មាឃ , មេឃ | ង : នាង , បង | |
| ច : ដូច , ក្រូច | ឆ : 0 | ជ : គជ |
| ឈ : 0 | ញ : ចេញ , ពេញ | |
| ដ : វដ្ត | ឋ : 0 | ឌ : មាឌ |
| ឍ : អាសាឍ | ណ : វណ្ណៈ | |
| ត : កើត , ជូត | ថ : ប្រមាថ , រថនាបថ | ទ : ប្រមាទ , វេទ |
| ធ : សុទ្ធសាធ | ន : ច្រើន | |

---

១. ព្យញ្ជនៈ ញ និង ព ទាំងពីរនេះ ម្នាក់ៗមានជើងពីរ ។ ចំណែក ឡ គ្មានជើងទេ តែអាចយកជើង ល មកប្រើជំនួសបាន ។ ២. សម្ល តម្លង់ សម្លុត សម្លឹង .... ។

ប : កើប　　ផ : ០　　ព : ភ័ព

ភ : លាភ　　ម : ដើម

យ : ដោយ, យាយ　　រ : ខ្ទុរ, កណ្ដុរ　　ល : វាល　　វ : ស្រាវ

ស : ពិសេស　　ហ : ០　　ឡ : ទមិឡ　　អ : ០

**២.ស្រៈ** (Vowel) គឺជាអក្សរដែលអាចបញ្ចេញសំឡេងខ្លួនឯងផង អាចធ្វើអោយព្យញ្ជនៈមានសូរសំឡេងផង ។ ស្រៈមានពីរប្រភេទគឺ :

**ក.ស្រៈផ្សំ(ស្រៈនិស្ស័យ)** គឺស្រៈប្រើជាមួយព្យញ្ជនៈរួមមាន៖

-ា -ិ -ី -ឹ -ឺ -ុ -ូ -ួ -ើ -ឿ -ៀ េ- ែ- ៃ- ោ- -ៅ -ុំ -ំ -ាំ -ះ -ុះ េ-ះ ោ-ះ ។ ស្រៈបន្ថែម៖ -ិះ -ឹះ ែ-ះ

**ខ.ស្រៈពេញតួ(ស្រៈសុទ្ធ)** គឺស្រៈដែលមានសំឡេងពេញលេញខ្លួនឯង និងអាចនាំព្យញ្ជនៈឱ្យចេញសំឡេងបានផងដែរ ។ ស្រៈពេញតួរួមមាន៖

អ អា, ឥ ឦ, ឧ ឩ, ឫ ឬ, ឭ ឮ, ឯ ឰ, ឱ ឳ

**៣.លេខ** (Number) គឺជាប្រភេទអក្សរដែលគេ ប្រើសំរាប់កត់ត្រាចំនួន ។

១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០

**៤.វណ្ណយុត្តិ** (Punctuation) គឺជាប្រភេទអក្សរដែលគេប្រើសំរាប់ផ្សំជាមួយព្យញ្ជនៈ ។

-វិសជ្ជនី/ រះមុខ(ះ)

- មូសិកទន្ត/ ធ្មេញកណ្ដុរ(៉)
- ត្រីសព្ទ/ សក់ក(៊)
- ទណ្ឌឃាត/ បដិសេធ(៍)
- របាទ(៌)
- បន្តក់(់)
- សំយោគសញ្ញា/ សញ្ញាផាត់លើ(័)
- លេខទោ(ៗ)
- លេខអស្តា/ លេខប្រាំបី(៏)
- ជើងក្អែក/ កាកបាទ/ សញ្ញាលេខបូក(+)
- ភ្នែកមាន់(៖)
- សញ្ញាខណ្ឌ/ ខណ្ឌសញ្ញា(។)
- សញ្ញាខណ្ឌចប់(៕)
- ឃ្នាប/ គាប([...] / {...})
- សញ្ញាវង់ក្រចក( (.....) )
- រជ្ជុសញ្ញា( - )
- សញ្ញាពងត្រី/ ចំណុចរាយ(.....)
- បេយ្យាល/ លៈ(។ល។)

- យុគលពិន្ទុ( : )

- សញ្ញាចុចមួយ( . )

- សញ្ញាក្បៀស( , )

- សញ្ញាចុចក្បៀស( ; )

- បុច្ឆនសញ្ញា/ សញ្ញាសួរ( ? )

- សញ្ញាឧទាន( ! )

- អព្ភន្តរសញ្ញា( «.....» / “.....” )

- សញ្ញាដំពីរ ( ៖ )

- សញ្ញានិង ( & )

វណ្ណៈយុត្តិខាងលើនេះ គឺមានលាយវណ្ណយុត្តិអន្តរជាតិខ្លះផង តែធ្លាប់ប្រើក្នុងភាសាខ្មែរយូរមកហើយដែរ ។

**៥.សទ្ទៈ** (Suond ) គឺជាឯកត្តាតូចបំផុត របស់ពាក្យ ។

ឧ. ែ + គ + ង > គែង( ែ , គ , ង គឺជាសទ្ទៈ) ។

**៦.ព្យាង្គ** (Syllable ) គឺជាសង្កាត់សូរសំឡេងនៃពាក្យ ។

ឧ១. សក់ , កាន់ , ស្រី , ប្រុស.... ពាក្យនីមួយៗទាំងនេះ មានសូរតែមួយម៉ាត់ គឺជាពាក្យមួយព្យាង្គ ។

ឧ២. ជីតា , កញ្ញា , កម្លោះ , បាត្អំ , .... ពាក្យនីមួយៗទាំងនេះ មាន

ស្ទូរពីរម៉ាត គឺជាពាក្យពីរព្យាង្គ ។ ពាក្យក្នុងភាសាខ្មែរ មានចាប់ពីមួយព្យាង្គ ដល់បួនព្យាង្គ ប៉ុន្តែក៏មានពាក្យមួយចំនួនតូចដែរ ដែលលើសពីបួន ព្យាង្គ ។

**៧.ពាក្យ** (Word ) គឺកើតឡើងពីការនិយាយស្តី ។ ពាក្យមានពីមួយម៉ាត់ ដល់ច្រើនម៉ាត់(មួយព្យាង្គ ដល់ច្រើនព្យាង្គ) ។

**៨.ឃ្លា** (Phrase )គឺជាល្បះសេចក្តី ដែលត្រូវដកអោយដាច់ឃ្លាត ជាខ្ទង់ៗក្នុងការនិយាយ ឬការសរសេរ ។ ឃ្លាជួនកាល ជាកំរងពាក្យមួយក្រុម ជួនជាល្បះមួយ ឬអាចជាល្បះលើសពីមួយថែមទៀតផង ។

**៩.ល្បះ** (Sentence )គឺកើតពីប្រធាន , កិរិយា និងអាចរួមបន្ថែមជាមួយ កម្មបទទៀតផង ។

**១០.កថាខណ្ឌ** (Paragraph )គឺកើតពីការរួមផ្សំរវាងល្បះច្រើនបញ្ចូលគ្នា ដើម្បី បង្ហាញគំនិតសំខាន់អ្វីមួយ ។

**១១.តែងសេចក្តី / អត្ថបទ** (Esay/text )គឺកើតពីការរួមផ្សំរវាង កថាខណ្ឌច្រើន បញ្ចូលគ្នា ។ តែងសេចក្តីរួមមានបីផ្នែកគឺ សេចក្តីផ្តើម, តួសេចក្តី និងសេចក្តីបញ្ចប់ ។

**១២.សៀវភៅ** (Book )គឺកើតពីតែងសេចក្តី/អត្ថបទច្រើនរួមបញ្ចូលគ្នា ។

| |
|---|
| *មិនខ្វះឡើយខសដុតបើនៅមានព្រៃ មិនខ្វត់ឡើយត្រីបើនៅមានបឹង* |
| *មិនខ្វះឡើយនូវការចេះដឹង ព្យាយាមទំប្រឹងរៀនគង់តែចេះ ។* |

# ពាក្យ

Word

**ពាក្យ**[១] (Word) គឺជាសំដីមួយម៉ាត់ឬច្រើនម៉ាត់(សូរសម្លេងដែលគេបន្លឺមួយដងឬច្រើនដង)ដែលមានន័យ និងទ្រង់ទ្រាយដោយឡែកៗពីគ្នានៃភាសា ។

ឧ. សិស្ស , កើត , គោ , ត្រី.... ។

ពាក្យចែកជាប្រភេទផ្សេងៗដូចជា៖

**១.ពាក្យពហុន័យ** (Homonym) គឺជាពាក្យមួយដែល អាននិងសរសេរដូចគ្នា ប៉ុន្តែមានន័យផ្សេងគ្នា ។ មានដូចជាពាក្យៈ ការ, ខ , កើត លោក... ។

**-ការ**

ឧ. សុក ការ នៅខែក្រោយ ។(កិ. រៀបអាពាហ៍ពិពាហ៍)

- គាត់ សំរេច ការ នោះហើយ ។(ន. ភារកិច្ច)

- មេមាន់នេះ ការ កូនបានល្អណាស់ ។(កិ. ថែរក្សា ការពារ)

- នាង ការ សរសៃសូត្របានល្អណាស់ ។(កិ. រៀបសូត្រជាដុំ)

---

១. ចំពោះអ្នកសិក្សាភាសា កាលណាគេនិយាយពីពាក្យ គឺគេគិតដល់ រូប(ទម្រង់) , សូរ , ន័យ , និង ថ្នាក់ពាក្យរបស់ពាក្យនោះ ។ តែចំពោះមនុស្សភាគច្រើន ដែលពុំមែនជាអ្នកសិក្សាលើភាសា ពាក្យគ្រាន់តែជាសំដីមួយម៉ាត់ឬច្រើនម៉ាត់មានន័យស្តាប់បាន ដើម្បីនិយាយឬសរសេរ ទាក់ទងគ្នា ក្នុងការរស់នៅតែប៉ុណ្ណោះ ។

-កើត

១. នាង កើត នៅឆ្នាំ ១៩៩០ ។(កិ. លេចមានឡើង)

-នៅថ្ងៃ១២កើត មានចន្ទគ្រាស ។(ន. ការរះឡើង)

-ថ្ងៃរះទិសខាងកើត និងលិចទិសខាងលិច ។(ឈ្មោះទិសខាង ព្រះអាទិត្យរះ គឺទិសបូព៌)

**២.ពាក្យន័យដូច**[២] (Synonym)គឺជាពាក្យមួយប្រភេទ ដែលសរសេរនិង អានខុសគ្នា ប៉ុន្តែមានន័យស្រដៀង ឬដូចគ្នា ។ មានដូចជាៈ ធំ =(សម្បើម, មហិមា ,ជ្រងោ) ,ក្រ=( គ្មាន ,ខ្សត់ ,ទាល់ ,អត្តខាត់ ,ខ្វះ)... ។

**៣.ពាក្យន័យផ្ទុយ**[៣] (Antonym)គឺជាពាក្យមួយប្រភេទ ដែលសរសេរនិង អានខុសគ្នា ហើយថែមទាំងមានន័យខុសគ្នាទៀតផង ។ មានដូចជាៈ មាន& ក្រ ,ល្អ &អាក្រក់ ,ខ្ពស់ &ទាប ,ទៅ &មក ,ចុះ &ឡើង ..... ។

**៤.ពាក្យសូរដូច**[៤] (Homophone)គឺជាមួយប្រភេទ ដែលមានសូរអានដូច គ្នា ប៉ុន្តែការសរសេរនិងអត្ថន័យខុសគ្នា ។ មានដូចជាៈ កាំ កម្ម ,កា ការ ការណ៍ កាណ...... ។

---

២. អ្នកខ្លះប្រើ ‘‘ពាក្យសទិសន័យ ,សទិសន័យ/សព្ទ ,វេវចនសព្ទ’’

៣. អ្នកខ្លះប្រើ ‘‘ពាក្យផ្ទុយ ,ពាក្យបដិន័យ ,វិសទិសន័យ/វិសទិសសព្ទ’’

៤. អ្នកខ្លះប្រើ ‘‘ពាក្យសទិសសូរ/សទិសសូរ ’’

**៥.សន្តានពាក្យ** (Family of Word) គឺជាពាក្យដែលមានន័យទាក់ទងគ្នា

មានដូចជាៈ ទស្សនៈ >(ទស្សនា ,ទស្សនីយភាព ,ទស្សនិកជន..)

កាំរិយកម្ម >(កាំរិយបរិច្ឆេទ ,កាំរិយាល័យ......) ។

ទស្សនៈន. ការឃើញ ,ដំណើរយល់ឃើញ ។ កាម

ទស្សនា កិ. មើល ។ កាន្បី សន្សី

ទស្សនីយភាព ន. រូបភាពដែលគួរអោយគយគន់ ។

ពាក្យទាំងបីខាងលើនេះសុទ្ធតែមានន័យ ទាក់ទងទៅនឹងការមើលដូចគ្នា

កាំរិយកម្ម(កាំរិ យៈ កាំ )ន. កិច្ចការ ដែលគេត្រូវធ្វើ ។

កាំរិយបរិច្ឆេទ ន. រយៈកាលកំណត់នៃកិច្ចការដែលត្រូវធ្វើ ។

កាំរិយាល័យ ន. កន្លែងធ្វើការ ,បន្ទប់ឬអគារធ្វើការ ។

ពាក្យទាំងបីខាងលើនេះសុទ្ធតែមានន័យ ទាក់ទងទៅនឹងការងារដូចគ្នា។

**៦.បរិវាសព្ទ** គឺជាពាក្យដែលសំរាប់យកទៅ ប្រើភ្ជាប់នឹងពាក្យផ្សេងៗ ទៀត ដើម្បីជាគ្នានឹងពាក្យទាំងនោះ វាអាចនៅមុខឬក្រោយពាក្យនោះ ។ បរិវាសព្ទប្រើតែឯងពុំមានន័យទេ តែបើប្រើជាមួយគេ វាជាអ្នកបញ្ជាក់ន័យ អោយពាក្យនោះទៅវិញ ។ ការដែលគេដឹងថា វាបញ្ជាក់ន័យអោយពាក្យវា អាស្រ័យជាមួយនោះ គឺដោយ[illegible]ទាធ្វើការគន្លាស់កាត់ ។

មានដូចជាៈ

ក្រមុំក្រមាច់(ពាក្យ " ក្រមុំ"យើងយល់ន័យវាហើយថា ស្រីពេញវ័យ តែចំណែកពាក្យថា" ក្រមាច់"យើងពុំអាចពន្យល់ន័យថាដូចម្តេចទេ តែគេអាចគន្លាស់កាត់ថា : ក្រមាច់ ពេញសុំ គឺ*ក្រមុំពេញសាច់*។)

ទូលំទូលាយ គឺទូលំធាយ មានន័យថាទូលាយធំ ។

ធូន់ធូរ គឺធូរពិបាកទ្រន់ មានន័យថាធូន់ពិបាកទ្រ ។

លំបាកលំបិន គឺលំបិនត្រឡប់ត្រឡាក មានន័យថា លំបាកត្រឡប់ត្រឡិន ។

........ ។

**៧.ពាក្យបំរៀបន័យ** (Metaphor) គឺជាពាក្យដែលគេប្រើប្រៀបប្រដូចវត្ថុមួយទៅវត្ថុមួយទៀត ។ ពាក្យបំរៀបន័យ មិនប្រើពាក្យចំណងធៀបទេ (ដូចជា ,ហាក់បីដូច..,) ។

មានពាក្យដូចជាៈ សំដីផ្អែម ,គុកកម្ម ,ដៃវន្ទះ ,ច្រមុះភ្នំ... ។

**៨.ពាក្យទំហៀបន័យ** (Simile)គឺជាពាក្យដែលប្រើប្រៀបប្រដូចវត្ថុមួយទៅវត្ថុមួយទៀត ។ ពាក្យទំហៀបន័យ គឺគេប្រើពាក្យចំណងធៀប(ដូចជា, ហាក់បីដូច ,...) ។

មានដូចពាក្យជាៈ ភក្ត្រដូចដួងខែ ,ខ្លាំងដូចគោ ,ល្អដូចទេវតា ... ។

៩.ពាក្យផ្សំ (Compound Word )គឺជាពាក្យដែល កើតឡើងដោយការផ្សំរវាងពាក្យនិងពាក្យចាប់ពីពីរពាក្យឡើងទៅ ។ ពាក្យនីមួយៗដែលយកមកផ្សំសុទ្ធតែមានន័យដោយឡែកៗពីកំណើតរបស់វា ប៉ុន្តែពេលដែលយកមកផ្សំគ្នា រួចហើយ វាបានក្លាយជាពាក្យមួយថ្មី មានន័យថ្មីមួយទៀត ។ ពាក្យផ្សំអាចកើតឡើងរវាងពាក្យនិងពាក្យ ដែលស្ថិតនៅក្នុងថ្នាក់ពាក្យជាមួយគ្នាឬរវាងពាក្យនិងពាក្យដែលស្ថិតនៅក្នុងថ្នាក់ពាក្យផ្សេងគ្នា ។

**ក. ពាក្យផ្សំជានាមផ្សំ** កើតឡើងពីៈ

- នាម + នាម=នាមផ្សំ

ឧ. ដំឡូងឈើ , នំទៀន , ឈើភ្លើង , ដៃភ្លើង , ជើងរន្ទះ នាងមេអំបៅ , តុបាយ , កាំបិតត្នោត... ។

- នាម + គុ. =នាមផ្សំ

ឧ.ឈើខ្មៅ , ដីស , ទឹកខ្មៅ ,... ។

- នាម + កិ. =នាមផ្សំ

ឧ. ស្លែក្តោប , ត្បាល់កិន , ដែកកេះ , ឈើច្រត់ , ដែកឈ្នូស. ។

- នាម + កិ. + នាម=នាមផ្សំ

ឧ. ឈើចាក់ធ្មេញ , ម៉ាស៊ីនច្រូតស្រូវ , ម៉ាស៊ីនបូមទឹក... ។

- គុណ. + នាម = នាមផ្សំ

ឧ. ខ្មៅដៃ , ពពាលខែ ,... ។

វិធីបង្កើតនាមផ្សំមួយចំនួនទៀតមានៈ

នាមផ្សំ កើតឡើងដោយការប្រើឈ្នាប់ចង "និង" ឬមិនចាំបាច់ប្រើឈ្នាប់ចង "និង" ក៏បាន ។

ឪពុកនិងម្តាយ > ឪពុកម្តាយ

បាយនិងសម្ល > បាយសម្ល

បងនិងប្អូន > បងប្អូន

ប្រុសនិងស្រី > ប្រុសស្រី..... ។

នាមផ្សំដោយប្រើពាក្យ "នានា" ឬសញ្ញាលេខទោ "ៗ"

នានាប្រទេស[1] / ប្រទេសនានា , នានាជាតិ / ជាតិនានា នានាវត្ថុនានា ,... ។

ស្រីៗ , កុមារៗ , ប្រុសៗ .... ។

ពាក្យផ្សំជាគុណនាមផ្សំ កើតឡើងពីៈ

- គុណ + នាម = គុណនាមផ្សំ

---

១. ការដាក់ពាក្យ "នានា" នៅខាងមុខគឺជាទំរង់បែបបាលី-សំស្ក្រឹត ។

ឧ. ក្ដៅចិត្ត , ធូន់ត្រចៀក , អាស្រូវកេរ្តិ៍.. ។

- កិ. + នាម=គុណនាមផ្សំ

ឧ. បាក់សាច់ , ចុះប្រេង , ក្ដៅចិត្ត ... ។

វិធីបង្កើតគុណនាមផ្សំមួយចំនួនទៀតមានៈ

គុណនាមផ្សំកើតឡើងដោយការប្រើឈ្នាប់ចង " និង " ឬមិនចាំបាច់ប្រើឈ្នាប់ចង " និង " ក៏បាន ។

ធំនិងធាត់>ធំធាត់ តូចនិងធំ>តូចធំ

វែងនិងខ្លី>វែងខ្លី ស្លូតនិងកាច>ស្លូតកាច

ធំនិងតូច>ធំតូច.... ។

គុណនាមផ្សំដោយប្រើសញ្ញាលេខទោ " ៗ "

តូចៗ , ទុំៗ , ចាស់ៗ , ថ្មីៗ , ស្រស់ៗ , ល្អៗ.... ។

ខ. ពាក្យផ្សំជាកិរិយាផ្សំ កើតឡើងពីៈ

- កិ. + នាម=កិរិយាផ្សំ

ឧ. ដើរតួ , ចាប់ចិត្ត , មានបំណង ,.. ។

កិរិយាផ្សំកើតឡើងដោយការប្រើឈ្នាប់ចង " និង " ឬមិនចាំបាច់ប្រើឈ្នាប់ចង " និង " ក៏បាន ។

ស្លៀកនិងពាក់>ស្លៀកពាក់

បោកនិងអ៊ុត>បោកអ៊ុត

ដកនិងស្ហូង>ដកស្ហូង

**១០.វិធីកំលាយ** គឺជាការបង្កើតពាក្យតាមវិធីជាក់លាក់មួយ របស់អ្ន

វេយ្យាករណ៍ មានពីរយ៉ាងគឺ៖

ក.វិធីកំលាយតាមផ្នត់ដើម គឺជាការយកព្យញ្ជនៈទៅដាក់ខាងដើម

ពាក្យរឹស ។

-ផ្នត់ដើម [ក-,ច-,ត-,ស-,......]

ក +កាយ>កកាយ , ក +បាំង>ក្បាំង

ច +បូត>ចបូត

ច +ចឹក>ចចឹក

ស +កក>ស្កក , ស +សិត>សសិត

-ផ្នត់ដើម [កង់-,អង់-,សង់-,......]

កង់ +វៀច>កង្វៀច

សង់ +កិន>សង្កិន

អង់ +កាច់>អង្កាច់

- ផ្នត់ដើម [ប្រ-, ស្រ-,......]

ប្រ + ទាញ>ប្រទាញ

ប្រ + ចាក់>ប្រចាក់

ស្រ + លះ>ស្រលះ

២.វិធីកំលាយតាមផ្នត់ជែក គឺជាវិធីយកព្យញ្ជនៈជែក ទៅជែកពាក្យ

។

- ផ្នត់ជែក [-ន-, -ម-, -ប-,......]

[-ន-] + កើយ>ខ្នើយ

[-ប-] + លង>ល្បង

- ផ្នត់ជែក [-អម់-, -អ៊ម់-, -អង់-, -អ៊ង់-, -អន់-, -អ៊ន់-,..]

[-អម់-] + ត្រូវ>តំរូវ/តម្រូវ

+ ត្រួត>តំរួត/តម្រួត

[-អ៊ម់-] + ជ្រាប>ជំរាប/ជម្រាប

+ ជ្រះ>ជំរះ/ជម្រះ

- ផ្នត់ជែក [-អ៊/ន-, -អ៊/ប-]

[-អ៊/ន-] + រុក>រនុក

+ រាស់>រនាស់

[-អ៊ិ/ប-] + រង>របង

+ រោយ>របោយ

ការបង្កើតពាក្យតាមវិធីកំលាយ ជាផ្នត់ដែកនិងផ្នត់ដើមនេះ គឺនៅមានច្រើនទៀត ។ ប៉ុន្តែការលើកយកមកនេះគ្រាន់តែចង់បញ្ជាក់ថា នេះជាវិធីបង្កើតពាក្យពិសេសរបស់ភាសាខ្មែរយើង ដែលភាសាដទៃពុំមានឡើយ ។

**១១.ពាក្យបន្ថែម** (Affix) គឺជាពាក្យសំរាប់បន្ថែមលើពាក្យរឹស[១] ។ មានពីរគឺបន្ថែមដើម និងបន្ថែមចុង ។

**ក. ពាក្យបន្ថែមដើម** (Preffix) គឺជាពាក្យសំរាប់បន្ថែមនៅខាងដើមពាក្យរឹស ហើយធ្វើអោយពាក្យរឹសមានន័យខ្ពស់ជាង ឬទាបជាងធម្មតា ឬធ្វើឲ្យពាក្យរឹសប្តូរទៅនៅថ្នាក់ពាក្យមួយផ្សេងទៀត ឬក៏មានន័យផ្ទុយពីធម្មតា ។

អភិ- =ក្រៃ ,ក្រៃលែង ,លើសលែង ,ប្រសើរថ្លៃថ្លា ,ណាស់ , ធំ ។

ឧ. អភិជន =ជនដែលប្រសើរថ្លៃថ្លា

អភិជ័យ=ជ័យជំនះក្រៃលែង

ភូ- =ផែនដី ,ពិភពលោក ,អ្នក... ។

---

១. ពាក្យរឹសឬគេហៅថាពាក្យកំណើត ។

ឧ. ភូគោល=គោលតំណាងផែនដី

ភូធន=អ្នកមានផែនដីជាទ្រព្យ

ភូបាល=អ្នកគ្រប់គ្រងផែនដី

សហ- =រួម ,ជាមួយ

ឧ. សហរដ្ឋ=រដ្ឋរួមគ្នា

សហប្រតិបត្តិការ=ប្រតិបត្តិការរួមគ្នា

អ- (អាក់)=មិន ,មិនមាន ,គ្មាន

អ + យុត្តិធម៌=អយុត្តិធម៌

+ សម្បុរស=អសប្បុរស

អតិ- =ក្រៃលែង ,បំផុត ,ណាស់ ,ពេក.. ។

អតិ + កល្យាណី=អតិកល្យាណី(ស្រីមានលំអក្រៃពេក)

+ ក្រិស=អតិក្រិស(ស្គមពេក)

អធិ- =ក្រៃលែង ,លើសលប់ ,លើ , ជាធំ.. ។

អធិ + បតី=អធិបតី

+ គុណ=អធិគុណ

អនុ- =បន្ទាប់ ,តូច ,តាម.. ។

បណ្ណាល័យ ហ៊ុន សែន HUN SEN LIBRARY R.U.P.P. សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

ការ-= ការស្រែកឃ្លាន ,ការស្អប់ខ្ពើម.. ។

ភាព-= ភាពសុខសាន្ត ,ភាពមានបាន.. ។

សេចក្តី- = សេចក្តីក្លាហាន ,សេចក្តីអាណិតអាសូរ.. ។

**ខ. ពាក្យបន្ថែមចុង(Suffix)** គឺជាពាក្យសំរាប់បន្ថែមនៅខាងចុងពាក្យរឹស ហើយធ្វើអោយពាក្យថ្មីមានន័យខ្ពស់ជាង ឬធ្វើអោយពាក្យថ្មីនោះប្តូរទៅនៅថ្នាក់ពាក្យមួយផ្សេងទៀត ហើយមានន័យប្លែកពីពាក្យរឹស ។

- ល័យ(អាល័យ)=ផ្ទះ ,លំនៅ ,សេចក្តីជាប់ចិត្ត ។

ឧ. បណ្ណាល័យ<(បណ្ណ + អាល័យ)

វិទ្យាល័យ<(វិទ្យ+ អាល័យ)

- គារ(អាគារ)=ផ្ទះ ,រោង

**ឧ.** បណ្ណាគារ<(បណ្ណ + អាគារ) ,រតនាគារ<(រតនៈ + អាគារ) សណ្ឋាគារ<(សណ្ឋ + អាគារ) ,ធនាគារ<(ធនៈ + អាគារ)

- បាល=ថែរក្សា ,ការពារ ,គ្រប់គ្រង

ឧ. ភូបាល=អ្នកគ្រប់គ្រងផែនដី ។

នគរបាល=អ្នករក្សានគរ អ្នករក្សាក្រុង ។

-ភាព/ -ធម៌=សភាព ,ភាវៈទ្រទ្រង់ ,បែបបទ ,ឫកពា

-ភាព ៖ សន្តិភាព ,សាមគ្គីភាព ,សុខភាព .. ។

-ធម៌ ៖ មនុស្សធម៌ ,វប្បធម៌ ,អរិយធម៌... ។

**១២.ពាក្យកំចី** គឺជាពាក្យដែលយើងយកពីភាសាដទៃមកប្រើ ដែល ត្រាប់តាមសូរសំលេងនៃភាសាណាមួយនោះ ។ ភាសាណាក៏ដោយក្នុង ពិភពលោកយើងនេះតែងតែមានពាក្យកំចី ពីបរទេសទាំងអស់ ពីព្រោះវា បានចូលមកប្រទេសនីមួយៗ តាមរយៈការទាក់ទងគ្នាតាមផ្លូវពាណិជកម្ម តាមផ្លូវនយោបាយ តាមការសិក្សាលើមុខវិជ្ជាផ្សេងៗ ។ការសរសេរពាក្យ កំចី ពុំសូវឯកភាពគ្នាទេ ពីព្រោះការយកពាក្យក្នុងភាសាគេ មកសរសេរជា ភាសាយើង វាមានការស្មុគស្មាញណាស់ ដោយម្នាក់ៗទាមទារយកតែត្រូវ រៀងៗខ្លួន ។ តែបើយើងមានគណៈ កម្មការមួយត្រឹមត្រូវនោះ ប្រហែល អាចសរសេរពាក្យកំចីមានការឯកភាពគ្នាភាគច្រើន ។

ពាក្យបារាំងថា(Sirop)៖អ្នកខ្លះសរសេរជាខ្មែរថា៖"ស៊ីរ៉ូ" ចំណែកខ្លះ ទៀតសរសេរថា៖"ស៊ីរ៉ូប៍" ។

ខ្មែរយើងមានពាក្យកំចីពីភាសាដទៃដូចជា៖

ក. ភាសាបាលី -សំស្រ្កឹត

ភាសាបាលី -សំស្រ្កឹត > ភាសាខ្មែរ

ប្រយោជន អានថា(ប្រយោ ជៈនៈ) ប្រយោជន៏ អានថា(ប្រយោច)

| ភាសាបារាំង | ភាសាខ្មែរ |
|---|---|
| Machine | ម៉ាស៊ីន |
| Métre | ម៉ែត្រ |
| Cassette | កាសែត..... |

ខ. ពីភាសាថៃ

កាពិ =ម្ហូបប្រៃធ្វើពីកំពឹស ឬបង្គាដែលគេបុកអោយល្អិត ។

ក្លូងខែក =ស្គរជ្វា គឺស្គរមួយប្រភេទដែលមានរាងវែង ពាសស្បែកទាំងសងខាង ។

ខុនណាង =ស្រីជាភរិយាមន្ត្រី ជំទាវខុនណាង ។

គ. ពីភាសាចិន

កៅអី =របស់សំរាប់អង្គុយ ។

គុយទាវ =ប្រភេទអាហារមានសរសៃដូចនំបញ្ចុក តែគេហូបវាជាមួយទឹកស៊ុប ។

ចុងភៅ =អ្នកដាំស្ល ។

..............

ឃ. ភាសាយួន

ខ្មែរ =ប្រដាប់សំរាប់កាប់ស្មៅ ។

ចាវ =ផ្អកចាវ ។

ដ =កំពង់ចំលង ។

................

**១៣.ពាក្យសំនួន** (Expression) គឺជាកំរងពាក្យដែលបង្កើតឡើង ដោយក្រុមអ្នកចូលចិត្តធ្វើការវិភាគ ពិចារណារកហេតុផល ។ ពេលគេនិយាយពាក្យទាំងនេះចេញធ្វើអោយអ្នកស្តាប់មានការកោតសរសើរ ហើយយល់ថាអ្នកនិយាយមានការចេះដឹងខ្ពស់ទៀតផង ។

ឧ. ត្រចៀកកាំមួយ មិនអាចបង្កើតនិទាឃរដូវបានឡើយ ។

- គេមិនអាចយកក្រដាសខ្ចប់ភ្លើងបានឡើយ ។

- សត្វខ្លាមានអំណាចពិតប្រាកដមែន ប៉ុន្តែបើវាមិនដើររកស៊ីទេច្បាស់ជាអត់ចំណី គឺគ្មានសត្វឯណារត់ចូលមាត់វាឡើយ ។

**១៤.ពាក្យស្លោក** (Slogan) គឺជាកំរងពាក្យពេចន៍ ដែលភាគច្រើនមានន័យត្រឹមត្រូវតាមតែសម័យកាលមួយៗប៉ុណ្ណោះ ។ តែមានពាក្យស្លោកខ្លះរឿយៗទៅ ក៏អាចក្លាយជា សុភាសិត បានដែរ ។ ពាក្យស្លោកដែលគេ

បង្កើតឡើង មានគោលបំណងផ្តល់ ឬប្រកាសព័តមានអំពីរឿងអ្វីមួយ ដើម្បីអោយមហាជនយល់ដឹងអំពីរឿងរ៉ាវនោះ ថាតើគេម្នាក់ៗមានភារកិច្ចក៏រិតណា ក្នុងការចូលរួមជាមួយរឿងរ៉ាវនោះ ។ ពាក្យស្លោកមានច្រើនប្រភេទគឺ ពាក្យស្លោកមានលក្ខណៈជាការអប់រំ , ពាក្យស្លោកមានលក្ខណៈជាបំរាម, ពាក្យស្លោកមានលក្ខណៈជាកាតព្វកិច្ច , ពាក្យស្លោកមានលក្ខណៈជាការអបអរសាទរ.. ។

- ទៅរៀននិងទៅបង្រៀន គឺស្នេហាជាតិ (មុនសម័យរដ្ឋកម្ពុជា)
- លក់ស្រូវជូនរដ្ឋ គឺស្នេហាជាតិ (មុនសម័យរដ្ឋកម្ពុជា)
- បណ្តុះបណ្តាលនៅក្នុងសាលា ផ្លែផ្កានៅក្នុងសង្គម
- យើងការពារបរិស្ថាន ព្រោះវាជាអាយុជីវិតរបស់យើង
- ជយោ ! ថ្ងៃបុណ្យឯករាជ្យជាតិ

**១៥.សុភាសិត** (Proverb) គឺជាកំរងពាក្យពេចន៍ ដែលភាគច្រើនមានន័យត្រឹមត្រូវស្មើរតែគ្រប់សម័យកាល ។

ចេះពីរៀន មានពីរក ។

តក់ៗពេញបំពង់ ឆុងៗកន្លះគ្រហែត ។

ស្លឹកឈើជ្រុះមិនឆ្ងាយពីគល់ ។

១៦.គ្រាមភាសា [១] (Dialect) គឺជាកំរងពាក្យពេចន៍ ឬពាក្យសំដីដែលអ្នកស្រុកបង្កើតឡើង ។ ពាក្យពេចន៍ប្រភេទនេះ អ្នកនៅក្រៅស្រុកមិនងាយយល់ឡើយ ។

- នៅប៉ែកបាត់ដំបង និងសៀមរាប

| | |
|---|---|
| សោ = អស់កំលាំង | របូត = របូត |
| កាក់ទុក = ឃាត់ទុក | លាម = ចងបន្លាយអោយវែង.. ។ |

- នៅប៉ែកស្វាយរៀង

| | |
|---|---|
| ចេវ = ស៊ូទ្រាំ | បាតេ / ប៉តេ = បាវ |
| លម = ឆ្អឹម | ឈ្នួត = ក្រមា..... ។ |

- នៅប៉ែកកំពត

គឺ = មែន (ក្មួយត្រូវការសៀវភៅនេះ គឺ?)

ពឹត = ប្រឹងប្រែង ប្រឹងមែនទែន

- នៅប៉ែកក្រចេះ

| | |
|---|---|
| ស្អិញ = ខ្ទាញ់ | ទឹករំលា = ទឹកជំនន់ ....... ។ |

[១] គ្រាម ជាភាសាសំស្ក្រឹតមានន័យថា ស្រុក ,ភូមិ ។

១៧.សាមញ្ញភាសា (Slang) គឺជាពាក្យឬកំរងពាក្យដែលគេនិយមប្រើបំផុតនៅក្នុងជីវភាពសាមញ្ញ ប៉ុន្តែភាសានេះគេមិនយកប្រើជាផ្លូវការទេ ។

*បែបទី១:*

- តូវសា =ទៅផ្សារ
- តើងៃនេះជាងៃអី ?=តើថ្ងៃនេះជាថ្ងៃអ្វី?
- តើឯងធើការអីដែរ? =តើឯងធ្វើការអ្វីដែរ?

*បែបទី២:*

- ជាប់កៅអី =ប្រលងជាប់ហើយបានរៀនបន្តទៀត ។
- ធ្លាក់កៅអី =ប្រលងជាប់សញ្ញាប័ត្រ តែមិនបានរៀនបន្តទៀតទេ ។
- ទាត់ខ្យល់ / ឬដើរទាត់ខ្យល់ =គ្មានការងារធ្វើ ឥតមុខរបរ ។
- គ្មានទុយយ៉ូប្រលងមិនជាប់ទេ =គ្មានបក្សពួកប្រលងច្បាស់ជាធ្លាក់ ។

ពាក្យទាំងបួនខាងលើកើតក្នុង សម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ។

ចំពោះអ្នករកស៊ីមានប្រើពាក្យដូចជា:

ធ្លាក់ទឹក=រកស៊ីខាត

កោរ=លក់ថ្លៃហួសពីធម្មតា, លក់យកតម្លៃខ្ពស់ពេក ។

ឡុងចុង=រកស៊ីខាត.......... ។



តើថ្នាក់ពាក្យជាអ្វី?



ថ្នាក់ពាក្យគឺជាក្រុមពាក្យ ដែលមានមុខងារផ្សេងៗគ្នា។



# ថ្នាក់ពាក្យ

Parts of Speech

**១.នាម** គឺជាពាក្យសំដែងប្រាប់ឈ្មោះមនុស្ស សត្វ រុក្ខជាតិ ទីកន្លែង គំនិត និងវត្ថុ ។

**២.សព្វនាម** គឺជាពាក្យសំរាប់ប្រើជំនួសនាម ឬកន្សោមនាម ។

**៣.កិរិយាសព្ទ** គឺជាពាក្យដែលបង្ហាញពីសកម្មភាពឬចលនា ។

**៤.គុណនាម** គឺជាពាក្យដែលបញ្ជាក់លក្ខណៈអោយនាម ឬសព្វនាម ។

**៥.គុណកិរិយា** គឺជាពាក្យសំរាប់បញ្ជាក់ បន្ថែមន័យអោយកាន់តែច្បាស់ ដល់ នាម គុណនាម កិរិយាសព្ទ ឬគុណកិរិយាដទៃទៀត ។

**៦.ធ្នាក់** គឺជាពាក្យសំរាប់ប្រើជាមួយនាម ឬសព្វនាមដើម្បីបង្ហាញថាតើ នាមឬសព្វនាមនោះ ជាប់ទាក់ទងនឹងពាក្យដទៃទៀត ក្នុងល្បះដូចម្តេច ។ ធ្នាក់តែងបង្ហាញប្រាប់: **ទិសដៅ ទីតាំង** ឬទាក់ទងទៅនឹងពេលវេលា ។

**៧.ឈ្នាប់** គឺជាពាក្យដែលសំរាប់ភ្ជាប់ពាក្យ ឬក្រុមពាក្យ ទៅនឹងពាក្យ ។

**៨.ឧទានសព្ទ** គឺជាពាក្យ ឬក្រុមពាក្យ ដែលអ្នកនិយាយបន្លឺសូរ របស់វាឮខ្លាំងខុសប្លែកពីធម្មតា ដើម្បីបង្ហាញអារម្មណ៍ភ្ញាក់ផ្អើល ,បង្ហាញ ពីការរំជួលចិត្តរបស់អ្នកនិយាយ ។

# អំពីនាម

Noun

**នាម** (Noun) គឺជាពាក្យសំដែងប្រាប់ឈ្មោះ មនុស្ស ,សត្វ ,រុក្ខជាតិ ទីកន្លែង ,គំនិត និងវត្ថុ ។

*សំគាល់មនុស្ស:* វិចិត្រករ ,សិស្ស ,សារុន ,គ្រូ ,កូនប្រសា........... ។

*សំគាល់ទីកន្លែង:* ភ្នំពេញ ,សារមន្ទីរ ,ស្រែ ,រោងកុន ,កីឡាដ្ឋាន..... ។

*សំគាល់វត្ថុ :* ឈើគូស ,ក្រដាស ,នាឡិកា ,គំនូរ ,ស្ពាន ,ផ្ទះ ,ទូក.. ។

*សំគាល់សត្វ:* ត្រី ,គោ ,មាន់ ,ចាប ,សេះ ,ពស់ ,ក្ងោក ,បង្កង..... ។

*សំគាល់រុក្ខជាតិ:* ស្វាយ ,ល្ហុង ,ទៀប ,ក្រូច ,ត្រសក់ ,ត្នោត ........ ។

*សំគាល់គំនិត:* សេរីភាព ,សុជីវធម៌ ,ពេលវេលា ,ប្រជាធិបតេយ្យ... ។

*សំគាល់អារម្មណ៍:* ការអត់ឃ្លាន ,ការអៀនខ្មាស ,ការសប្បាយ ,ការច្រណែន សេចក្ដីឈ្នានីស...... ។

*សំគាល់ចរិតលក្ខណ:* ភាពរឹងរូស ,បញ្ញា ,សប្បុរស... ។

## នាមចែកជា:

**១.នាមសាធារណ៍** (Common Noun) គឺជានាមបង្ហាញប្រាប់ឈ្មោះ មនុស្ស ,សត្វ ,រុក្ខជាតិ ,ទីកន្លែង ,វត្ថុ ឬគំនិត·ក្នុងលក្ខណៈ ទូទៅ ។

*សំគាល់មនុស្ស:* កសិករ ,គ្រូ ,ស្ដេច ,កម្មករ ,អ្នកនិពន្ធ ,ម្ដាយ.. ។

*សំគាល់សត្វ:* សេះ ,មាន់ ,គោ ,ចាប ,ត្រី ,អណ្ដើក ,ដង្កូវ.. ។

*សំគាល់កន្លែង:* ទីក្រុង ,វាលស្រែ ,សមរភូមិ ,កីឡាដ្ឋាន..... ។

*សំគាល់វត្ថុ:* ផ្ទះ ,ទូរទស្សន៍ ,ឡាន ,យន្តហោះ ,ជណ្ដើរ ,ស្បែកជើង ក្រមា ,ស្ពាន..... ។

*សំគាល់គំនិត:* សេចក្ដីស្រឡាញ់ ,មនោសញ្ចេតនា ,ឧត្តមគតិ ,សាសនា សេចក្ដីអាណិត.... ។

**២.នាមអសាធារណ៍** (Proper Noun) គឺជានាមបង្ហាញប្រាប់ឈ្មោះ មនុស្ស ,សត្វ ,រុក្ខជាតិ ,ទីកន្លែង ,វត្ថុ ឬគំនិត ក្នុងលក្ខណៈពិតប្រាកដ សំដៅចំៗឈ្មោះ ។

*សំគាល់មនុស្ស:* ឥន្ទ្រទេវី ,ក្រឡាហោមគង់ (វីរៈបុរសខ្មែរប្រឆាំងនឹងបារាំង),អៀវកើស ,សីហនុ ,ស៊ិន ស៊ីសាមុត ,ភិរម្យង៉ុយ , អង្គដួង, ភិក្ខុសោម ,ណាប៉ូឡេអុង , ប៊ូស(ប្រធានាធិបតីអាមេរិក) ...... ។

*សំគាល់សត្វ:* អាចំប៉ា(គោ) ,តូនី(ឆ្កែ) ,អាស្លឹក(សេះ)... ។

*សំគាល់កន្លែង:* អ្នកលឿង ,ស្ទឹងត្រែង ,ភ្នំពេញ ,បាភ្នំ ,កំពត កំពង់ស្ពឺ ,ព្រៃនគរ ,ព្រៃវែង ,ព្រះវិហារ ,សៀមរាប ,កោះត្រល់.. ។

*សំគាល់វត្ថុ:* អង្គរវត្ត ,មហាកំពែងចិន,វិមានឯករាជ្យ ,ប៊ិចបែន (ឈ្មោះនាឡិកានៅក្រុងឡុង) ,ទួអេហ្វែល(ឈ្មោះវិមានដ៏ខ្ពស់មួយនៅក្រុងប៉ារីស) ។

*សំគាល់រុក្ខជាតិ:* ស្វាយខ្ចិះ ,ចេកអំបូង ,ដូងភ្លើង.......... ។

*សំគាល់គំនិត:* លទ្ធិក្រហម , លទ្ធិព្រះពុទ្ធ ,លិទ្ធកុម្មុយនីស, លទ្ធិប្រជាធិបតេយ្យ........... ។

**៣.សមូហនាម** (Collective Noun) គឺជានាមបង្ហាញចំនួនច្រើន ។ សមូហនាមមានដូចជាៈ ក្រុម , ពួក , អង្គភាព , ហ្វូង , សមាគមន៍ , កង , បក្ស សមូហភាព , និកាយ , កម្រង...... ។

**៤.នាមផ្សំ** (Compound Noun) គឺជានាមមួយប្រភេទ កើតឡើងដោយការផ្សំពីៈ ន.+ន. , ន.+កិ. , ន+គុ. និងគុ.+ន. ។

ឧ. កូនធម៌ , ឈើគូស , អាវរងា , មិត្តប្រុស , ផ្ទះបាយ , មាត់ទ្វារ ដីស , ទ្រនាប់ជើង / ស្បែកជើង ....... ។

*-នាមផ្សំកើតពីៈ ន.+ន.*

មិត្ត + ប្រុស>មិត្តប្រុស

ផ្ទះ + បាយ>ផ្ទះបាយ

ទ្រនាប់ + ជើង>ទ្រនាប់ជើង... ។

*-នាមផ្សំកើតពីៈ ន.+កិ.*

ឈើ + គូស>ឈើគូស

ត្បាល់ + កិន>ត្បាល់កិន

ដែក + ឈូស>ដែកឈូស.... ។

*-នាមផ្សំកើតពីៈ ន.+គុ.*

ឈើ + ខ្មៅ>ឈើខ្មៅ

ទឹក + ខ្មៅ>ទឹកខ្មៅ

ដី + ស>ដីស

បណ្ណាល័យ ហ៊ុន សែន HUN SEN LIBRARY R U P P

*-នាមផ្សំកើតពី: គុ +ន.*

ខ្មៅ + ដៃ>ខ្មៅដៃ

ពពាល + ខែ>ពពាលខែ..... ។

**៥.នាមរូបី**(Concrete Noun) គឺជានាមមួយប្រភេទ ដែលបង្ហាញឲ្យដឹងតាមរយៈវិញ្ញាណណាមួយ នៃអង្គវិញ្ញាណទាំងប្រាំរបស់យើង ។

នាមរូបីមានដូចជា: គោ , មាន់ , ផ្ទះ , វត្ត , ឡាន......... ។

***ចំណាំ :*** *ទេវតា , យក្ស , ព្រះឥន្ទ្រ*.......ក៏ជានាមរូបីដែរ ពីព្រោះនាមទាំងនេះគេអាចយកមកគូរវាសកើតជារូបរាងបាន ។

**៦. នាមអរូបី** (Abstract Noun) គឺជាប្រភេទនាមសាធារណ៍ ដែលបង្ហាញពីគំនិត ហើយគំនិតនោះ មិនអាចបង្ហាញឲ្យឃើញឬដឹងបាន តាមរយៈវិញ្ញាណណាមួយ ក្នុងចំណោមវិញ្ញាណទាំងប្រាំរបស់យើង ( ភ្នែក, ច្រមុះ , ត្រចៀក , អណ្តាត , និងអង្គកាយ)ឡើយ ។

នាមអរូបីមានដូចជា: *ការទូន្មាន , សោភណភាព* , ចំណេះវិជ្ជា , *ការងារ , មរណភាព , ព័ត៌មាន , សេចក្តីអាណិត , សេចក្តីសង្ឃឹម* ,.... ។

**៧.នាមជីវចល** គឺជានាមទាំងឡាយណា ដែលមានជីវិតប្រកបដោយញាណ និងមានសកម្មភាពរស់រវើក ដើម្បីជីវិតរស់នៅ ។ នាមជីវចលសំដៅយកលើមនុស្ស និងសត្វនេះតែម្តង ។


HUN SEN LIBRARY

**៨.នាមអជីវចល** គឺជានាមទាំងឡាយណា ដែលមានជីវិតឬមានជីវិតដែរ តែពុំមានសកម្មភាពក្នុងការរស់នៅទេ ។

នាមអជីវចលមានដូចជា: *ដើមដូង , ផ្ទះ , ឡាន , រទេះ , សៀវភៅ.....* ។

**៩.នាមករណ៍ឬករណនាម** គឺជានាមសំដែងសភាពសកម្ម ។

នាមនេះកើតឡើងពី:

***-កិរិយាសព្ទ:***

ធ្វើ >ទង្វើ , សង្កេត >ការសង្កេត............ ។

***-គុណនាម:***

សុខ >សេចក្តីសុខ , ក្តៅ >កំដៅ , ល្អ > លំអ..... ។

១០.នាមការក៍ឬការកនាម គឺជានាមសំដែងប្រាប់ឈ្មោះអ្នកធ្វើអំពើ ឬអ្នកមានសភាពលក្ខណៈបែបណាមួយ ។ នាមនេះកើតឡើងពី:

***-កើតពី : កិរិយាសព្ទ+អ្នក***

យាម>អ្នកយាម , ពោល>អ្នកពោល , ច្រៀង>អ្នកច្រៀង... ។

***-កើតពី : គុណនាម+អ្នក***

ល្អ>អ្នកល្អ , អាក្រក់ >អ្នកអាក្រក់ , សុខ>អ្នកសុខ...... ។

កំ.សំ:នាមការណ៍បែបបាលី -សំស្ក្រឹតមាន"ករ ,ជន" នៅខាងចុង ។

កម្ម+ ករ=កម្មករ ,កីឡា+ ករ=កីឡាករ ,នាដ+ ករ=នាដករ.... ។

បេក្ខ+ ជន=បេក្ខជន ,វរ:+ជន=វរជន ,មហា+ ជន=មហាជន... ។

*-កើតពី : នាម+អ្នក*

ភូមិ>អ្នកភូមិ ,ភ្នំ>អ្នកភ្នំ ,ចំការ>អ្នកចំការ ,ក្រុង>អ្នកក្រុង.. ។

**១១.វចនៈរបស់នាម** គឺមានពីរប្រភេទ នាមឯកវចនៈនិង នាមពហុវចនៈ ។

*ក.នាមឯកវចនៈ:* គឺជានាមបង្ហាញប្រាប់ចំនួនមួយ គឺមនុស្សម្នាក់ កន្លែងមួយ ,វត្ថុមួយ ,ឬគំនិតមួយ ។

ឧ. សុក ជាសិស្សពូកែ ។ សុកជានាមឯកវចនៈពីព្រោះវាបញ្ជាក់ប្រាប់ចំនួនមនុស្សតែម្នាក់ ។

*ខ.នាមពហុវចនៈ:* គឺជានាមប្រាប់ចំនួនច្រើន ។ មានដូចជា: ប្រជាជន ,ជនានុជន ,គ្រួសារ ,បរិស័ទ ,បរិវារ........... ។

ឧ. សិស្សានុសិស្ស នៅ ក្នុងថ្នាក់រៀន ។ សិស្សានុសិស្ស ជានាមពហុវចនៈពីព្រោះវាបញ្ជាក់ប្រាប់ចំនួនសិស្សច្រើន ។

**១២.ភេទនៃនាម** គឺមានបីភេទប្រុស ,ភេទស្រី ,និងអភេទ។

នាមនីមួយៗតែងតែមានភេទរបស់វា ។

ឧ. កុមារី (ភេទ ស្រី)

ឧ. ឡាន (អភេទ) ។

នាមនីមួយៗអាចស្ថិតក្នុងប្រភេទ ច្រើនយ៉ាងដូចជា: [ ( នាមសាធារណ៍/ ...ាមអសា- )+ (ជីវចល/ អជី)+ (មនុស្ស/ អមនុ- ), (ភេទ: ប្រុស/ស្រី/ អភេទ)

+(រូបី/អរូបី)+(ឯក-ពហុវចន)]:

សំ ជា សិស្ស ។

សំ គឺជា " នាម -អសាធារណ៍
-មនុស្ស
-ជីវចល
-រូបី
-ឯកវចនៈ" ។

សិស្ស គឺជា "នាម -សាធារណ៍
-ជីវចល
-មនុស្ស
-រូបី
-ឯកវចនៈ" ។

ចំណាំ: ភាសាខ្មែរយើងសុទ្ធនាមឬសព្វនាម ពុំមានភេទនិងវចនៈច្បាស់លាស់ទេ នាមឬសព្វនាមទាំងអស់សុទ្ធសឹងតែអភេទ ។បើចង់ប្រាប់ភេទរបស់នាម ឬសព្វនាមគឺគ្រាន់តែប្រើពាក្យ"ប្រុសឬស្រី"បើចង់ប្រាប់វចនៈរបស់នាមគ្រាន់តែប្រើពាក្យប្រាប់ចំនួន" តិច ,ច្រើន ,មួយ ,ពីរ.."ប៉ុណ្ណោះ ។ តែបើនាមក្លាយមកពី បាលី-សំស្ក្រឹតវិញ ទើបមានភេទនិងវចនៈ របស់វា ។

ឱ. សិស្ស -ភេទ=អភេទ
-វចនៈ=ឯកវចនៈ ។

សិស្សានុសិស្ស - ភេទ=អភេទ

- វចនៈ=ពហុវចនៈ ។

ឧ. បុត្រា - ភេទ=ប្រុស

- វចនៈ=ពហុវចនៈ ។

បុត្រី - ភេទ=ស្រី

- វចនៈ=ឯកវចនៈ ។

**១៣.មុខងារនៃនាមក្នុងល្បះ**

នាមប្រើបានជាប្រធាន ឬកម្មបទនៃល្បះ ។

***ក.នាមប្រើជាប្រធាននៃល្បះ***

ឧ. មុន្នីរ័ត្ន សប្បាយចិត្តណាស់ថ្ងៃនេះ ។

ឧ. សិស្ស មករៀនប្រាំថ្ងៃក្នុងមួយសប្តាហ៍ ។

ពាក្យ "មុន្នីរ័ត្ន , សិស្ស" ជាប្រធានរបស់ល្បះទាំងពីរខាងលើ ។

***ខ.នាមប្រើជាកម្មបទនៃល្បះ***

ឧ. សាលា ផ្តល់រង្វាន់អោយ មុន្នីរ័ត្ន ។

ឧ. គ្រូ បង្រៀន សិស្ស ។

ពាក្យ "មុន្នីរ័ត្ន , សិស្ស" ជាកម្មបទក្នុងល្បះទាំងពីរខាងលើ ។

# អំពីសព្វនាម

Pronoun

**សព្វនាម**(Pronoun) គឺជាពាក្យសំរាប់ប្រើជំនួសនាម ឬកន្សោមនាម ។

សព្វនាមមានៈ *គាត់ , វា , ឯង , យើង , ខ្ញុំ , គេ , នាង , ដែល , នេះ...* ។

## I.សព្វនាមរួមមានៈ

**១.សព្វនាមបុរិសៈ**(Personal Pronoun) គឺជាសព្វនាម ដែលមានការប្រើប្រាស់ចាំបាច់បំផុត ។

សព្វនាមបុរិសៈចែកចេញជាបីបុរស(បីក្រុម)ដូចខាងក្រោម :

| | | |
|---|---|---|
| *ក.បុរសទី១:* | ឯកវចនៈ | ពហុវចនៈ |
| | ខ្ញុំ (យើង) | យើង ពួកយើង |
| *ខ.បុរសទី២:* | ឯង | ពួកឯង |
| *គ.បុរសទី៣:* | នាង | ពួកនាង |
| | វា | ពួកវា |
| | គាត់ | ពួកគាត់ |
| | គេ | ពួកគេ |

*ឃ.ភេទរបស់សព្វនាមបុរិសៈ* សព្វនាមទាំងនេះពុំមានចែកភេទច្បាស់លាស់ឡើយ គឺអាស្រ័យលើនាមដែលវាជំនួសឲ្យតែប៉ុណ្ណោះ បើនាមនោះជាភេទអ្វី សព្វនាមក៏មានភេទដូច្នោះដែរ ។

ឧ. សុធារី ជាសិស្សថ្នាក់ទី៧ ។ **នាង** មករៀនមិនដែលយឺតទេ ។(សព្វនាម"នាង"គឺភេទស្រី ។)

ឧ. សេង ជាកសិករ ។ **គាត់** មានកូនពីរនាក់ ។(សព្វនាម"គាត់ " គឺអភេទដោយសារនាម"សេង"ដែលសព្វនាម"គាត់ "ជំនួសឲ្យគឺជានាមអភេទ ។ ពីព្រោះកសិករឈ្មោះ"សេង"មិនដឹងជាប្រុសឬស្រីទេ ។ )

ឧ. មីងសេង ជាកសិករគំរូ ។ **គាត់** បានទទួលបណ្ណសរសើរពីលោកមេឃុំ ពីម្សិលមិញ ។ (សព្វនាម"គាត់"គឺភេទស្រី ដោយសារនាម"សេង" ដែលសព្វនាម"គាត់ "ជំនួសឲ្យគឺភេទស្រី ។

ឧ. លោកសេង ជាអ្នកនិពន្ធ ។**គាត់** និពន្ធសៀវភៅភាសាខ្មែរ ។ (សព្វនាម"គាត់ " គឺភេទប្រុស ដោយសារនាម "សេង"ដែលសព្វនាម "គាត់ "ជំនួសឲ្យគឺភេទប្រុស ។

**២.សព្វនាមចង្អុល** (Demonstrative Pronoun) គឺជាសព្វនាមសំរាប់ចង្អុលប្រាប់ ទីជិត ឬឆ្ងាយ ។

***ក.សំរាប់ទីជិត:*** គេប្រើពាក្យ *នេះ*

ឧ. នេះ ជាតុរបស់រស្មី ។

ឧ. នេះ ជាចំណែកឯង ។

***ខ.សំរាប់ទីឆ្ងាយ:*** គេប្រើពាក្យ ***នោះ***

ឧ. នោះ ជាភ្នំកង្រី ។

(សូមមើលការប្រៀបធៀបគុ. ចង្អុលនិងសព្វនាមចង្អុលនៅទំព័រ ៦១)

ឆ្លៀតម៉ាត់ = សុះម៉ាត់

**៣.សព្វនាមសំនួរ** (Interrogative Pronoun) គឺប្រើសំរាប់សួរ ។ *នរណា , អ្នកណា , អ្វី , អ្នកណាខ្លះ.........* ។

ឧ. **អ្នកណាខ្លះ** ទៅសួរសុខទុក្ខ លោកតា?

(សូមមើលការប្រៀបធៀបសព្វនាមសំនួរ និងគុ. សំនួរ នៅទំព័រ ៦២)

**៤.សព្វនាមឈ្នាប់** (Relative Pronoun) មានតែមួយគត់គឺ **ដែល** ។ សព្វនាមឈ្នាប់ ប្រើជំនួស នាម កន្សោមនាម ឬឃ្លានាម ។

ឧ. ចោរ **ដែល**លួចកង់ឯង គេចាប់បានហើយ ។(ជំនួស ន.)

ឧ. សុខានិងដានី **ដែល**ជាសិស្ស ត្រូវបានទៅរៀននៅជប៉ុន ។(ជំ. ក. ន.)

ឧ. ពិសិដ្ឋជាវិចិត្រករ **ដែល** មានស្នាដៃល្អជាងគេ ។(ជំនួស ឃ្លា ន.)

**៥.សព្វនាមឆ្លុះ**(Reflexive Pronoun) គឺកើតឡើងនៅក្នុងល្បះ វាជាអ្នកធ្វើនិងទទួលអំពើដោយខ្លួនឯងផ្ទាល់ ។ សព្វនាមឆ្លុះមានដូចជាៈ *ផ្ទាល់ខ្លួន ដោយខ្លួនឯង ដោយខ្លួននាង ដោយពួកគេ........* ។

ឧ. ខ្ញុំ ខឹងនឹង **ខ្លួនឯង** ។

ឧ. គាត់ ប្រក់ផ្ទះ **ខ្លួនឯង** ។

**៦.សព្វនាមមិនច្បាស់** (Indefinite Pronoun) សំដៅចំពោះនាមទាំងឡាយណាដែល**សព្វនាមមិនច្បាស់** ជំនួសអោយនោះមានលក្ខណៈមិនអាចបង្ហាញប្រាប់អោយឃើញភាពច្បាស់លាស់បាន ។ សព្វនាមមិនច្បាស់ វាប្រើ

ជំនួសអោយនាម ស្ថិតក្នុងលក្ខណៈទូទៅ ដោយមិនបញ្ជាក់ច្បាស់ចំពោះនាមណាមួយឡើយ ។ សព្វនាមមិនច្បាស់មានដូចជាៈ *នរណាម្នាក់ , អ្នករាល់គ្នា , នរណាមួយ....* ។

ឧ. **អ្នករាល់គ្នា** ត្រូវទៅឡើងឡាន នៅម៉ោង៦ព្រឹក ។

ឧ. តើ **អ្នករាល់គ្នា** ចង់បានអ្វី? (សព្វនាមមិនច្បាស់ ប្រើជាសំនួរ)

(សូមមើលការប្រៀបធៀបគុ. មិនច្បាស់និងសព្វនាមមិនច្បាស់នៅទំព័រ ៦២)

## II.មុខងារនៃសព្វនាមក្នុងល្បះ

សព្វនាមមាននាទី ជាប្រធាននៃល្បះផងនិងជាកម្មបទនៃល្បះផង ។

*ក.នាទីជាប្រធាន*

ឧ. គាត់ ភ្ជួរស្រែ ។

ឧ. **យើង** រៀនភាសាខ្មែរ ។

ឧ. នាង មកពីស្រុកកំណើត ។

*ខ.នាទីជាកម្មបទ*

ឧ. ធី តា ជួប គាត់ ។

ឧ. ឪពុកនាង ចូលចិត្ត ខ្ញុំ ។

# តើកិរិយាសព្ទជាអ្វី ?









កិរិយាគឺជាពាក្យដែលបង្ហាញពីចលនា ឬសកម្មភាព។





# កិរិយាសព្ទ

Verb

**កិរិយាសព្ទ** (Verb) គឺជាពាក្យដែលបង្ហាញប្រាប់ ពីសកម្មភាព ឬចលនា ។ កិរិយាសព្ទមានដូចជាៈ ច្រៀង, កសាង ,ស្រឡាញ់ ,ដើរ .... ។

**១.កិរិយាសព្ទសុទ្ធ**(Root Verb) គឺជាកិរិយាសព្ទ សំដែងនូវអំពើរបស់ប្រធាន ដែលប្រធានជាអ្នកសម្រេចអំពើដោយខ្លួនឯងផ្ទាល់ ។

ឧ. សិស្ស **ដាំ** ផ្កាក្នុងសួន ។

-កសិករ **ស្ទូង** ស្រូវ ។

-ឆ្កែ **ប្រោល** ។

**២.កិរិយាសព្ទហេតុ**(Causative Verb) គឺជាកិរិយាសព្ទសំដែងនូវអំពើ របស់ប្រធានដែលធ្វើឡើងគ្រាន់ជាដើមហេតុប៉ុណ្ណោះ ឯកម្មបទជាអ្នកទទួលយកបុព្វហេតុនោះ ទៅធ្វើអំពើអោយសម្រេចដោយខ្លួនឯង ។

ឧ. គ្រូ **បង្រៀន** សិស្ស ។

ម្តាយ **បំបៅ** កូន ។

ក្នុងឧទាហរណ៍ខាងលើពាក្យ **គ្រូ ម្តាយ** ជាប្រធាននៃល្បះ ។ ឯពាក្យ **បង្រៀន** និង **បំបៅ** ជាកិរិយាសព្ទហេតុ ។ ចំណែកពាក្យ **សិស្ស** និង **កូន** ជាកម្មបទ ។

ប្រធាននីមួយៗនៃល្បះទាំងពីរខាងលើ បានធ្វើអំពើរបស់ខ្លួនតាមរយៈកិរិយាសព្ទហេតុ **បង្រៀន** និង **បំបៅ** ប៉ុន្តែអំពើរបស់ប្រធានក្នុងល្បះទាំង

ពីរខាងលើនេះ គ្រាន់តែជាហេតុផ្តើមឡើង ដើម្បីអោយកម្មបទធ្វើអំពើ ដោយខ្សែកមួយទៀត ដោយខ្លួនឯងផ្ទាល់តែប៉ុណ្ណោះ ។

**កិរិយាសព្ទហេតុកើតពី:**

| | | | | | |
|---|---|---|---|---|---|
| **កិ-សុទ្ធ** | **→** | **កិ-ហេតុ** | **កិ-សុទ្ធ** | **→** | **កិ-ហេតុ** |
| សាយ | > | ផ្សាយ | ផ្អើល | > | បង្អើល |
| សឹក | > | ផ្សឹក | កើត | > | បង្កើត |
| **គុណនាម** | **→** | **កិ-ហេតុ** | **គុណនាម** | **→** | **កិ-ហេតុ** |
| គាប់ | > | ផ្គាប់ | ក្តៅ | > | កំដៅ |
| រាប | > | ពង្រាប | ទុំ | > | បន្ទុំ |
| ខ្ទេច | > | កំទេច | ពេញ | > | បំពេញ |

**៣.កិរិយាសព្ទសកម្ម** (Transitive Verb) គឺជាកិរិយាសព្ទត្រូវការកម្មបទផ្ទាល់ជាចាំបាច់ ។

ឧ. ពូម៉ៅ កាប់ ឈើ ។

ពិសិដ្ឋ និទាន រឿង ។

កិរិយាសព្ទ : **កាប់** *និង* **និទាន** ជាកិរិយាសកម្ម ។ នាមៈ **ឈើ** និង **រឿង** ជាកម្មបទផ្ទាល់ នៃកិរិយាសព្ទ **កាប់** និង **និទាន** ។

**ចងចាំ:** កម្មបទផ្ទាល់ប្រាប់ពី **អ្វី** ឬ **នរណា** វាមិនប្រាប់ពី ពេលណា កន្លែងណា ឬយ៉ាងដូចម្តេច ទេ ។

ឧ.រតនា ឃើញ ពស់មួយ ។ (ឃើញ អ្វី?)

**កិរិយាសព្ទសកម្ម កើតពី:**

| **កិ-អកម្ម → កិ-សកម្ម** | | | **កិ-អកម្ម → កិ-សកម្ម** | | |
|---|---|---|---|---|---|
| ដេក | > | ផ្ដេក | ដួល | > | ផ្ដួល |
| ហើរ | > | បង្ហើរ | ហោះ | > | បង្ហោះ |
| **គុណនាម →កិ-សកម្ម** | | | **គុណនាម →កិ-សកម្ម** | | |
| សើម | > | ផ្សើម ,បន្សើម | សល់ | > | បន្សល់ |
| សាប | > | បន្សាប | យល់ | > | ពន្យល់ |

**៤.កិរិយាអកម្ម**(Intransitive Verb) គឺជាកិរិយាសព្ទមិនទាមទារនូវកម្មបទទេ ។

ឧ.ក្មេង យំ ។

-នាង ច្រៀង ពីរោះណាស់ ។

ឧ.ពស់ លូន លឿនណាស់ ។ (លូន ដូចម្ដេច? មិនអាចថា លូនអ្វីបានឡើយ)

**ចងចាំ:** កិរិយាអកម្ម ថ្នាក់ពាក្យនៅបន្ទាប់ពីវា មានដូចជា: គុណកិរិយា ,ធ្នាក់ និង ឈ្នាប់ ។

ឧ. គាត់ **និយាយ** *ជាមួយ* រតនា ។ (កិរិយាអកម្ម+ ធ្នាក់)

កំ.សំ កិរិយាសព្ទខ្លះ អាចជាកិរិយាសព្ទសកម្មផង ជាកិរិយាសព្ទអកម្មផង ។

ឧ.ភ្លើង *ឆេះ* ខ្លាំងណាស់(កិរិយាសព្ទអកម្ម) ។ ភ្លើង *ឆេះ* ផ្ទះ(កិរិយាសព្ទសកម្ម) ។

ឧ. វា **រត់** *លឿនណាស់* ។ (កិ. អកម្ម+ គុ. កិ)

ឧ. គាត់ **ចេះ** *តែ* គាត់ធ្វើជាល្ងង់ ។(កិ. អកម្ម+ ឈ្នាប់ចង)

ឧ. ខ្ញុំ**ដឹង** *ថា* គាត់មកវិញហើយ ។(កិ. អកម្ម+ ឈ្នាប់ឃ្លា)

**៥.កិរិយាចំណង**(Linking Verb) គឺជាកិរិយាសព្ទសំរាប់ចងភ្ជាប់រវាងនាម ឬ សព្វនាមប្រធាន ទៅនឹងពាក្យឬកន្សោមពាក្យដែលបញ្ជាក់ន័យអោយ នាមឬសព្វនាមប្រធាននោះវិញ ។

ឧ. សំ ជា សិស្ស ។

- វា ក្លាយជា កីឡាករ ។

- នាង ជា អ្នកចំរៀងល្បីម្នាក់ ។

កិរិយាចំណងគឺតែងតែត្រូវការគុណនាមផងដែរ ដើម្បីបញ្ជាក់ន័យអោយនាមឬសព្វនាមនោះ ។

ឧ. សុវ៉ាន់ ប្រែជា ស្លូតគ្រាន់បើឥឡូវ ។

**កិរិយាចំណងមាន:**

**ក. កិរិយាចំណងធម្មតា:** *គឺ ជា គឺជា*

**ខ. កិរិយាចំណងប្លែកពីធម្មតា:** *ក្លាយជា ប្រែជា បែរជា ត្រឡប់ជា មុខជា ហាក់ដូចជា* ....... ។

**៦.កិរិយាសព្ទជំនួយ**(Helping Verbs) គឺជាកិរិយាសព្ទសំរាប់ប្រើជំនួយដល់កិរិយាសព្ទសំខាន់ដទៃទៀត ។ កិរិយាសព្ទជំនួយមិនអាចប្រើតែឯងបានទេគឺវា ប្រើសម្រាប់តែជំនួយដល់កិរិយាសំខាន់ៗប៉ុណ្ណោះ ។

ឧ. ខ្ញុំ ចង់ ទៅ អាមេរិក ។

-គាត់ ត្រូវតែ ឈ្នះ ។

-ខ្ញុំ ប្រាថ្នា ទិញ ឡានថ្មីមួយ ។

-វា ហ៊ាន ចូល ក្នុងរូងខ្លា ។

កិរិយាសព្ទជំនួយមានដូចជាៈ *ហ៊ាន , ត្រូវតែ , ប្រាថ្នា , ចង់ , គួរតែ , បាននឹង , មុខជា , ប្រហែល , ប្រហែលជា ...............* ។

**៧.នាមកិរិយានិងគុណនាមកិរិយា**(Verbal noun & Verbal adjective)

**ក.នាមកិរិយា** គឺជានាមអាចប្រើជាកិរិយាបាន ។

នាមកិរិយាមានដូចជាៈ *ផ្លែ , ភ្លៀង , ទូរសព្ទ* ........ ។

ឧ. ស្វាយ ផ្លែ ច្រើនណាស់ ។

-យប់មិញ ភ្លៀង ច្រើនណាស់ ។

-ខ្ញុំ *បានទូរសព្ទ* ទៅ គាត់ហើយ ។

-ត្របយើង ផ្កា ច្រើនណាស់ ។

**ខ.គុណនាមកិរិយា** គឺជាគុណនាមអាចប្រើជាកិរិយាបាន ។គុណនាមកិរិយាមានៈ *ទុំ , ក្រហម , ជោរ*......... ។

ឧ. ស្រូវគាត់ ទុំ ស្រុះណាស់ ។

-ល្ងាចនេះទឹក ជោរ ពេញព្រែកតែម្តង ។

# កាលកិរិយាសព្ទ

**កាលកិរិយាសព្ទ** គឺនិយាយអំពីពេលវេលា នៃកិរិយាសព្ទ ។កិរិយាសព្ទអាចចង្អុលប្រាប់ពីពេល អតីតកាល ,បច្ចុប្បន្នកាល ឬ អនាគតកាល ។កាលកិរិយាសព្ទចែកជាបីគឺ:

**១.កិរិយាសព្ទបច្ចុប្បន្ន** គឺជាកិរិយាសព្ទសំរាប់ប្រើក្នុងបច្ចុប្បន្ន ។

ខ្ញុំ **ធ្វើ** ស្រែ ។ គាត់ **ជីក** ប្រឡាយ ។ ម្តាយ **បំពេរ** កូន ។

ខ្ញុំ *កំពុង* **សរសេរ** ។ នាង *កំពុង* ច្រៀង ។

ពាក្យ "កំពុង" ជាពាក្យសំរាប់ជំនួយកិរិយាសព្ទបច្ចុប្បន្ន អោយមានភាពវិសេសប្លែកជាងកិរិយាសព្ទបច្ចុប្បន្នធម្មតា ដោយបង្ហាញអោយឃើញ ឬដឹងថា សកម្មភាពមួយកំពុងមានចលនា ប្រព្រឹត្តទៅចំពោះមុខមិនទាន់ចប់នៅឡើយ ។

**២.កិរិយាសព្ទអតីតកាល** គឺជាកិរិយាសព្ទសំរាប់សំដែងប្រាប់ពីសកម្មភាពអ្វីមួយ ដែលបានកើតឡើងក្នុងពេលកន្លងផុតមកហើយ ។

ឧ. ខ្ញុំ *បាន* **ជួប** គាត់ម្សិលមិញ ។

ឧ. គាត់ *ទើបនឹង* **មក** អំបាញ់មិញនេះ ។

ពាក្យជំនួយសំរាប់អោយកិរិយាសព្ទបច្ចុប្បន្ន ក្លាជាកិរិយាសព្ទអតីតកាល ។ មានដូចជា: *បាន* ,*ទើប* ,*រួចហើយ* ,*កន្លងមក*...... ។

កំ.សំ កិរិយាសព្ទអតីតកាលខ្លះ បង្ហាញកាលកន្លងមកហើយផង និងកាលបច្ចុប្បន្នផង ។

ឧ. ខ្ញុំ បានរស់នៅ ភ្នំពេញយូរឆ្នាំហើយ ។ (អតីត រួមជាមួយ បច្ចុប្បន្ន)

ឧ. ខ្ញុំ បានរស់នៅ ភ្នំពេញបីឆ្នាំដែរ ។ (អតីតកាល)

**៣.កិរិយាសព្ទអនាគតកាល** គឺជាកិរិយាសព្ទសំដែងប្រាប់សកម្មភាព ឬព្រឹត្តិការណ៍ដែលនឹងកើតឡើងនៅពេលខាងមុខ ។

ឧ. គាត់ **នឹងទៅ** ស្រុកកំណើតថ្ងៃស្អែក ។

- នាង **នឹងទៅ** សិក្សានៅអាមេរិក ខែក្រោយនេះ ។

- ពិធីបុណ្យ នឹងប្រព្រឹត្តទៅ នៅថ្ងៃស្រុកនេះ ។

ពាក្យជំនួយសំរាប់អោយកិរិយាសព្ទបច្ចុប្បន្ន ក្លាយជាកិរិយាសព្ទអនាគតកាល ។ មានដូចជាៈ *នឹង , គង់នឹង , មុខនឹង , បំរុងនឹង , ប្រាកដនឹង នឹងបាន........* ។

**សូមចងចាំថា** កិរិយាសព្ទក្នុងភាសាខ្មែរយើង ពុំមានការប្រែរូបលក្ខណៈពីកិរិយាបច្ចុប្បន្ន ទៅអតីតកាល ដូចជាភាសាបារាំង អង់គ្លេសទេ កិរិយាសព្ទក្នុងភាសាខ្មែរយើង គឺគ្រាន់តែបន្ថែមពាក្យ "**បាន**" នៅខាងដើម កិរិយាបច្ចុប្បន្ន កិរិយាបច្ចុប្បន្ននោះ នឹងក្លាយជាកិរិយាអតីតកាលហើយ ៕

> *អយុត្តិធម៌ ការវាសរមិនល្អ ច្រើនតែវង្វេង ធ្វើការភ្លេចភ្លាំង ព្រោះគិតរឿងផ្សេង រឿងគិបរឿងកេង ផលផ្ទាល់អាត្មា ។*

# តើគុណនាមជាអ្វី?







**គុណនាម** គឺជាពាក្យសំរាប់បង្ហាញប្រាប់ពីលក្ខណៈ ឬទ្រង់ទ្រាយ អោយនាម។
មានពាក្យដូចជា: *ល្អ, អាក្រក់, តូចធំ, មូល, ជ្រុង, ខ្ពស់, ទាប, ជាដើម* ។



# អំពីគុណនាម

Adjective

**គុណនាម** (Adjective) គឺជាពាក្យដែលសំរាប់ បញ្ជាក់លក្ខណៈអោយនាម ឬសព្វនាម ។

មានដូចជា: *ធំ , តូច , ច្រើន , តិច , ទាប , ខ្ពស់ , ក្រហម , លឿង ជ្រុង , ចាស់ , ថ្មី , នេះ , នោះ , អ្វី , ពីរ , បី , ណាមួយ .....* ។

ឧ. ផ្ទះ ថ្មី ; តុ វែង ; អាវ លឿង ។

## គុណនាមរួមមាន:

**១.គុណនាមប្រក្រតី** (Common Adj.) គឺគុណនាមទាំងឡាយណា ដែលសម្រាប់យកមក ធ្វើការពិពណ៌នា លើនាមឬ សព្វនាម ។ គុណនាមប្រក្រតីបញ្ជាក់ប្រាប់ផងដែរអំពី **ប្រភេទអ្វី នៃ** នាមឬ សព្វនាម ។

គុ. ប្រក្រតីបញ្ជាក់ -គុណភាព ហៅថា គុ. គុណភាព
-បរិមាណ ហៅថា គុ. បរិមាណ
-ពណ៌សម្បុរ ហៅថា គុ. ពណ៌ ។

គុណនាមប្រក្រតីមាន: *ក្ដៅ , ក្រាត , លឿង , ក្រហម , ល្អ , អាក្រក់, ផ្អែម , ឆ្លាត , ខ្ពស់ , ទាប , វែង , ខ្លី , ខ្លី , ទុំ , សាប , ប្រៃ , ថ្លៃ , ថោក , ក្រមាន , ស្រស់ , ស្អាត , ចាស់ , ថ្មី ,........* ។

ឧ. កង់តូច ជិះមិនបានលឿនទេ ។

-ធារី ជាសិស្សល្អ ។

**១ក.គុណនាមគុណភាព** (Adj. of Quality) គឺជាគុណនាមសំរាប់ប្រាប់ពីលក្ខណៈឬសភាពនៃនាម ។

ឧ.ផ្ទះ ចាស់

-ត្រី ស្អុយ

-សិស្ស ឆ្លាត

ពាក្យ ស្អុយ ចាស់ ឆ្លាត ជាគុណនាមគុណភាព ។

**១ខ.គុណនាមបរិមាណ** (Adj. of Quantity) គឺជាគុណនាមសំរាប់បញ្ជាក់ពីបរិមាណ ។

ឧ.ត្រីច្រើន ,ភ្លៀង ធំ

ពាក្យ ច្រើន ធំ បញ្ជាក់បរិ មាណ ។

**១គ.គុណនាមពណ៌** (Adj. of Colour) គឺសំរាប់ប្រាប់ពណ៌ផ្សេងៗ ។

គុណនាមពណ៌មាន: *ស ,ខ្មៅ ,ខៀវ ,បៃតង ,ក្រហម,លឿង.,....* ។

ឧ.ប៊ិច ក្រហម , អាវ ស ; សៀវភៅ លឿង......... ។

ពាក្យ ក្រហម ,ស ,លឿង បញ្ជាក់ប្រាប់ពណ៌ ។

**២.គុណនាមចង្អុល** (Demonstrative Adj.) ជាគុណនាមសំរាប់ចង្អុលប្រាប់ វត្ថុ មនុស្ស សត្វ ឬអ្វីៗ ដែលនៅចំពោះមុខទាំងជិត ទាំងឆ្ងាយ ។

នាឡិកា នេះ

គោ នេះ

ពាក្យ នេះ សំរាប់ចង្អុលប្រាប់ទីជិត ។

ភ្នំ នោះ

កោះ នោះ

ពាក្យ នោះ សំរាប់ចង្អុលប្រាប់ទីឆ្ងាយ ។

(សូមមើលការប្រៀបធៀបគុ. ចង្អុលនិងសព្វនាមចង្អុលនៅទំព័រ៦១)

**៣.គុណនាមមិនច្បាស់** (Distributive Adj.) គឺជាគុណនាមដែលបង្ហាញប្រាប់អ្វីមួយមិនច្បាស់លាស់ ។

ឧ. ក្មេង រាល់គ្នា

-សៀវភៅ អ្វី

(សូមមើលការប្រៀបធៀបសព្វ. មិនច្បាស់ និងគុ. មិនច្បាស់នៅទំព័រ៦២)

**៤.គុណនាមចំនួន** (Quantitative Adj.) គឺជាគុណនាម សំរាប់ប្រាប់ចំនួន ។ គុណនាមចំនួនចែកជាពីរ គឺចំនួនរៀប និងចំនួនរាប់ ។

ឧ. សៀវភៅ ដប់ ក្បាល

-យន្តហោះ ប្រាំ

ពាក្យ ដប់ ប្រាំ ជាគុណនាមចំនួនរាប់ ។

ឧ. គាត់ ឈរជួរ ទីពីរ

-នាង រៀនថ្នាក់ ទី៥

ពាក្យ ទីពីរ ទី៥ ជាគុណនាមចំនួនរៀប ។

**៥.គុណនាមសំនួរ** (Interrogative Adj.) គឺជាគុណនាមសំរាប់សួរពីអ្វីមួយ ។

ឧ. តើម៉ូតូ **ណាមួយ** ជារបស់ ឯង?

(សូមមើលការប្រៀបធៀបសព្វ. សំនួរ, គុ. សំនួរ និងគុ. កិសំនួរទំព័រ៦២)

**៦.គុណនាមកម្មសិទ្ធិ** (Possessive Adj.) គឺជាគុណនាមសំរាប់ប្រាប់ម្ចាស់នៃរបស់អ្វីមួយ ។ គុណនាមកម្មសិទ្ធិមានពីរគឺគុណនាមកម្មសិទ្ធិសាធារណ៍ និងគុណនាមកម្មសិទ្ធិអសាធារណ៍ ។

ឧ. កាតាបខ្ញុំ ,ប៊ិចសុខា ,ឡានចាន់ណា ,កង់ **សុផាត**........ ។

ពាក្យ ខ្ញុំ ,សុខា ,ចាន់ណា ,សុផាត ជាគុណនាមកម្មសិទ្ធិអសាធារណ៍ ។

ឧ. សៀវភៅ **សិស្ស**

-គោ **កសិករ**............... ។

ពាក្យ **សិស្ស** ,កសិករ ជាគុណនាមកម្មសិទ្ធិសាធារណ៍ ។

**៧.កំរិតប្រៀបធៀបនៃគុណនាម** (Comparison of Adj.)

| **កំរិតធៀបស្មើ** | **កំរិតធៀបលើស** | **កំរិតធៀបបណ្តាច់** |
|---|---|---|
| ល្អ ដូច | ល្អជាង | ល្អបំផុត |
| ខ្ពស់ដូច | ខ្ពស់ជាង | ខ្ពស់ណាស់ |
| ពូកែដូច | ពូកែជាង | ពូកែណាស់ |

ឧ. គាត់ គឺល្អដូច ខ្ញុំ ។

- ឆាង គឺល្អជាង ជានី ។
- កាត់ គឺខ្ពស់ណាស់ ។

## ៨.ការវិភាគគុណនាម

*ក.គុ.ប្រក្រតីឬគុ.បរិមាណ:*

- ត្រី ច្រើន ; ផ្ទះ ធំ

ពាក្យ ច្រើន , ធំ ជាគុ.ប្រក្រតីបញ្ជាក់បរិមាណ វាជាគុ.បរិមាណ ។

*ខ.គុ.ប្រក្រតីឬគុ.គុណភាព:*

- ឡានចាស់ ,ត្រី ស្អុយ

ពាក្យ ចាស់ ស្អុយ ជាគុ.ប្រក្រតីបញ្ជាក់គុណភាព វាជាគុ.គុណភាព ។

*គ.គុ.ប្រក្រតីឬគុណនាមពិណ:*

- ខ្មៅដៃ ក្រហម ; សណ្ដាគារ ខៀវ

ពាក្យ ក្រហម ខៀវ ជាគុណនាមប្រក្រតីបញ្ជាក់ប្រាប់ពិណ វាជាគុណនាមពិណ ។

គុណកិរិយារួមមាន:

១.គុណកិរិយាបំណែប (Adverb of Manner)

មានៈ លឿន ,យឺត ,រហ័ស ,រឿយៗ..................... ។

២.គុណកិរិយាកាល (Adv. of Time)

មានៈ ថ្ងៃស្អែក ,ម្សិលមិញ ,អំបាញ់មិញ ,ថ្ងៃមុន.......... ។

*គុណកិរិយានៃភាពញឹកញាប់ (Adverb of Frequency)

មានៈ រឿយ , រាល់សប្តាហ៍......... ។

៣.គុណកិរិយាកន្លែង (Adverb of Place)

មានៈ ខាងលើ ,ខាងក្រោម ,ខាងក្រៅ ,ឆ្ងាយ ,ជិត ,ខាងមុខ , ក្រោយ. ។

៤.គុណកិរិយាបរិមាណ (Adverb of Degree)

មានៈ ណាស់ ,ច្រើន ,តិច ............... ។

៥.គុណកិរិយាសំនួរ (Interrogative Adverb )

មានៈ ហេតុអ្វី ,ដូចម្តេច.................. ។

# អំពីគុណកិរិយា

Adverb

**គុណកិរិយា** ( Adverb ) គឺជាពាក្យសំរាប់បញ្ជាក់ន័យបន្ថែមអោយ កាន់តែច្បាស់ដល់ គុណនាម , កិរិយាសព្ទ , ឬគុណកិរិយាដទៃទៀត ។

*ក.គុ.កិ.បញ្ជាក់ន័យអោយកិរិយាសព្ទ:*

- អ្នករៀនចប់ បានរង់ចាំ ។(តើរង់ចាំដូចម្តេច? ពេលណា? កន្លែងណា?)

**ដូចម្តេច:** អ្នករៀនចប់ បានថធរង់ចាំ **យ៉ាងអន្ទះសា** ។

**កន្លែង:** អ្នករៀនចប់ បានរង់ចាំ **ខាងក្រៅ** ។

**ពេល:** អ្នករៀនចប់ បានរង់ចាំ **ថ្ងៃនេះ** ។

*ខ.គុ.កិ.បញ្ជាក់ន័យអោយគុណនាម:*

- សន្ទរកថានេះ វែង ។

\+ សន្ទរកថានេះ វែង**ណាស់** ។

*គ.គុ.កិ.បញ្ជាក់ន័យអោយគុណកិរិយាដទៃទៀត:*

- ទស្សនិកជន អបអរ ខ្លាំងក្លា ។

\+ ទស្សនិកជន អបអរ ខ្លាំងក្លា ណាស់ ។

- អ្នកចប់ការសិក្សា បានសើច សប្បាយ ។

\+ អ្នកចប់ការសិក្សា បានសើច សប្បាយ**យ៉ាងខ្លាំង** ។

**ចំណាំ :** ត្រូវចងចាំថា បើគុ. កិ. បញ្ជាក់ន័យអោយ គុ. ឬគុ. កិ. ដទៃទៀត វាតែងតែ ឆ្លើយនឹងសំនួរ *តើវាស្ថិតដល់កំរិតណា?*

មាន: លឿន , ញាប់ , ណាស់ , តែងតែ , យ៉ាង ...... ។

Iគុណកិរិយារួមមាន:

**១.គុណកិរិយាបំណែ** (Adverb of Manner) គឺជាគុណកិរិយា បង្ហាញពីបែប បទ នៃសកម្មភាព ឬសភាពលក្ខណៈ ។គុណកិរិយាបំណែប មានដូចជា : លឿន, យ៉ាងលឿន, យឺត, យ៉ាងយឺត, រហ័ស, យ៉ាងរហ័ស, រឿយៗ, អង់អាច, យ៉ាងអង់អាច , សប្បាយ , យ៉ាងសប្បាយ , ស្ងាត់ស្ងៀម , យ៉ាងស្ងាត់ស្ងៀម, ស្ទាត់ , ស្ទាត់ណាស់ .......... ។

*ក-គុ.កិ បំណែបនៅបន្ទាប់ពី កិរិយាសព្ទ(កិរិយាអកម្ម)*

ឧ. ធារី រាំ **ស្អាតណាស់** ។

- វា ស៊ី **ញាប់** ។

- នាង ស្តាប់ **យ៉ាងយកចិត្តទុកដាក់** ។

*ខ-គុ.កិ បំណែបនៅបន្ទាប់ពី កម្មបទ*

ឧ. សុផា និយាយ ភាសាអង់គ្លេស **ស្ទាត់ណាស់** ។

*គ-គុ.កិ បំណែបនៅបន្ទាប់ពី កិ.+ធ +កម្មបទ*

ឧ. វា ខឹង នឹង ខ្ញុំ **ខ្លាំងណាស់** ។

- សុរិន រត់ ឡើងផ្ទះ **យ៉ាងលឿន** ។

**២.គុណកិរិយាកាល** (Adv. of Time) គឺជាគុណកិរិយាបង្ហាញប្រាប់ពី ពេលវេលា ។ គុណកិរិយាកាលមានដូចជា: *ថ្ងៃស្អែក* , *ម្សិលមិញ*, *ថ្ងៃមុន* , *អំបាញ់មិញ* ,.......... ។

ឧ. គាត់ នឹងទៅ **ឥឡូវនេះ** ។

ឧ. **ថ្ងៃស្អែក** ខ្ញុំ ទៅ ភ្នំពេញ ។

***គុណកិរិយានៃភាពញឹកញាប់** (Adverb of Frequency) គឺជាគុណ កិរិយា បង្ហាញប្រាប់ពីសកម្មភាពមួយ ដែលកើតឡើងយ៉ាងញឹកញាប់ ឬរឿយៗ ។ គុណកិរិយានៃភាពញឹកញាប់មានដូចជា: *រឿយៗ , តែងតែ , រាល់សប្តាហ៍ ញឹកញាប់.........* ។

ឧ. នាង **តែងតែ** ទៅរៀន រាល់ថ្ងៃ ។

- វា ជួនកាល មិនទៅរៀនទេ ។
- អ្នក **មិនដែល** ទៅប្រជុំទេ ។
- ខ្ញុំ **តែងតែ** មកទាន់ពេល ។

**៣.គុណកិរិយាកន្លែង** (Adverb of Place) គឺជាគុណកិរិយាបង្ហាញប្រាប់ទីកន្លែង ។ គុណកិរិយាកន្លែងមានដូចជា: *ខាងលើ , ខាងក្រោម , ខាងក្រៅ ឆ្ងាយ , ជិត , ខាងមុខ , ក្រោយ...* ។

ប្រសិនបើល្បះពុំមានកម្មទេ គុណកិរិយាកន្លែង តែងតែនៅបន្ទាប់ពីកិរិយាសព្ទ ។

ឧ. នាង ទៅ **ក្រៅហើយ** ។

- គាត់ រស់នៅ **ឯបរទេស** ។
- តើ អ្នក **ទៅទីណា?**

**៤.គុណកិរិយាបរិមាណ** (Adverb of Degree) គឺជាគុណកិរិយាបង្ហាញពីបរិមាណ ,ពីទំហំ ,ពីវិសាលភាព ។ គុណកិរិយាបរិមាណមានដូចជាៈ *ណាស់ ច្រើន ,តិច ,លំបាក ,ស្អាត ,ល្មម ,អស្ចារ្យ ,សមរម្យ ,ពេញលេញ....* ។

*ក.គុណកិរិយាបរិមាណនៅបន្ទាប់ពីកិរិយា*

ឧ. សុធី និយាយ យ៉ាងច្រើន អំពីបញ្ហានោះ ។

-វា យំ ខ្លាំងណាស់ ។

*ខ.គុណកិរិយាបរិមាណនៅបន្ទាប់ពីគុណនាម*

ឧ. តារា ចាប់បាន ត្រីធំ ណាស់ ។

-ខ្ញុំ ឃើញ ពស់ធំណាស់ ។

-ប្រអប់នេះ គឺតូចណាស់ ។

*គ.គុណកិរិយាបរិមាណនៅបន្ទាប់ពីកម្មបទ*

ឧ. ខ្ញុំ ស្រឡាញ់ នាង ពិតប្រាកដ ។

**៥.គុណកិរិយាសំនួរ**(Interrogative Adverb) គឺជាគុណកិរិយាសំរាប់យកទៅប្រើជាសំនួរ ។ គុណកិរិយាសំនួរមានដូចជាៈ *ទីណា ,អង្កាល , ហេតុអ្វី , ដូចម្តេច*................. ។

*ហេតុៈ* -ហេតុអ្វីបានជា ឯងមិនទៅធ្វើការ?

-ហេតុដូចម្តេចបានជា វាយំខ្លាំងម្លេះ?

-ហេតុអ្វីបានជា ឯងមកយឺត?

**កន្លែងៈ** -តើអ្នករស់នៅ ទីណា?

-តើឯងមកពីទីណា?

**កាល:** -តើឯងមក **អង្កាល** ?

-តើឯងទៅវិញថ្ងៃណា ?

-តើអ្នកភ្ញាក់ពីដេកស្មានណា ?

(សូមមើលការប្រៀបធៀបសព្វ គុ. និងគុ.កិសំនួរ ទំព័រ ៦២)

**៦.គុណកិរិយាឈ្នាប់**(Relative Adverbs)**មាន:**កាល កន្លែង និងហេតុ ។

**ហេតុ:** -នៅឆ្នាំ **ដែល** ប្រទេសយើង មានសង្គ្រាម ។

-នៅថ្ងៃ **ដែល** ពួកគេ ទៅព្រៃវែង ។

**កន្លែង:** -សណ្ឋាគារ **ដែល** ពួកគេស្នាក់នៅ ។

**ហេតុ:** -សេចក្តីអះអាងនោះហើយជាហេតុ **ដែល** គាត់ធ្វើការបដិសេធន៍ ។ ហេតុ **ដែល** គាត់បដិសេធន៍ គឺដោយសារសេចក្តីអះអាងនោះ ។(The reason why he refused is../ Why he refused is that reason.)

## II.គុណកិរិយាប្រៀបធៀប:

ទំរង់ប្រៀបធៀបនៃគុណកិរិយា គឺគេយកទៅធ្វើការប្រៀបធៀបគ្នារវាងសកម្មភាពពីរ ។ ទំរង់បណ្តច់នៃគុណកិរិយាគឺគេយកទៅធ្វើការប្រៀបធៀបគ្នា រវាងសកម្មភាពចាប់ពីរឡើងទៅ ។

ឧ.គាត់ ដើរ **យឺតជាង** ខ្ញុំ (ដើរ) ។ ខ្ញុំ រត់ **លឿនដាច់** គេ(រត់) ។

គុណកិរិយាប្រៀបធៀប មានលក្ខណៈស្រដៀងគ្នានឹងគុណនាមប្រៀប

ធៀបដែរ ។ ប៉ុន្តែគុណកិរិយាប្រៀបធៀប ប្រៀបធៀបតែផ្នែកសកម្មទេ ។ រីឯគុណនាមប្រៀបធៀបវិញ ធ្វើការប្រៀបធៀបលក្ខណៈនៃនាមនិងនាម ។

## III.ការប្រៀបធៀបពាក្យតែមួយ នៅក្នុងថ្នាក់ពាក្យផ្សេងគ្នា

### ១.ការប្រៀបធៀបគុណចង្អុលនិងសព្វនាមចង្អុល

#### ក.គុណនាមចង្អុល

គាត់ស្រឡាញ់ សៀវភៅ នេះ ។ តុនោះ ជារបស់សំ ។

(ពាក្យ នេះ បញ្ជាក់ន័យអោយ *សៀវភៅ* ឯពាក្យ នោះ បញ្ជាក់ន័យអោយ *តុ*។ ដូច្នេះពាក្យ នេះ និងនោះជាគុណនាម វាចង្អុលប្រាប់វត្ថុនៅទីចំពោះមុខអ្នកនិយាយនិងអ្នកស្តាប់ ។)

#### ខ.សព្វនាមចង្អុល

នេះ ជាសៀវភៅសិស្ស ។ នោះ ជាវត្តទឹកថ្លា ។

(ពាក្យ នេះ តំណាងអោយ*សៀវភៅ* ឯពាក្យនោះ តំណាងអោយ*វត្ត*។ ដូច្នេះពាក្យ នេះ និងនោះ ជាសព្វនាម វាជំនួសអោយវត្ថុនៅទីចំពោះមុខអ្នកនិយាយនិងអ្នកស្តាប់ដូចគុណនាមផងដែរ ។)

### ២.ការប្រៀបធៀបគុណនាមកម្មសិទ្ធិ និងសព្វនាម

| គុ.កម្មសិទ្ធិ | សព្វនាម |
|---|---|
| -សុផា ជាកូន គាត់ ។ | គាត់ ទៅផ្សារ ។ |
| -ស្រូវគាត់ គឺល្អណាស់ ។ | សិស្សទៅសួរសុខទុក្ខ គាត់ ។ |

ចំណាំ : គុណនាមកម្មសិទ្ធិនិងសព្វនាម គឺជាពាក្យមានរូបលក្ខណៈ ដូចគ្នា។ពាក្យ"ខ្ញុំ គាត់ វា យើង ឯង នាង ពួកគេ........"គឺជាគុណនាមកម្មសិទ្ធិផង ជាសព្វនាមផង ។

## ៣.ការប្រៀបធៀបគុណនាមមិនច្បាស់ និងសព្វនាមមិនច្បាស់

| គុ.មិនច្បាស់ | សព្វ.នាមមិនច្បាស់. |
| --- | --- |
| សិស្សរាល់គ្នា មករៀន ។ | រាល់គ្នា យល់ថាត្រូវធ្វើអ្វីហើយ ។ |
| តើលោកមានសល់ ក្រូច ខ្លះទេ? | ខ្ញុំមានសល់ ខ្លះ ដែរ ។ |
| សិស្សម្នាក់ៗ ត្រូវពាក់អាវស ។ | ម្នាក់ៗ ទទួលបានបន្ទាត់មួយ ។ |
| តើលោក មានលុយ ខ្លះ ទេ? | ខ្ញុំមាន ខ្លះ ដែរ ។ |

## ៤.ការប្រៀបធៀបសព្វ. សំនួរ គុ. សំនួរ និងគុ.កិ សំនួរ

ឧ.មានសៀវភៅបីក្បាលនៅលើតុ តើមួយណា ជារបស់ឯង ?

(ពាក្យ "មួយណា" ជាសព្វនាមសំនួរ វាឈរជំនួសអោយ សៀវភៅ ។)

ឧ.តើម៉ូតូមួយណា ជារបស់ ឯង ?

(ពាក្យ"មួយណា"គុណនាមសំនួរ ពីព្រោះពាក្យនេះ វានៅបន្ទាប់ពីនាម "ម៉ូតូ" វាមានតួនាទីបញ្ជាក់ន័យអោយម៉ូតូ ។)

ឧ.តើឯង មក អង្កាល ?

(ពាក្យ"អង្កាល"ជាគុណកិរិយា វាបំពេញន័យអោយកិរិយា"មក" ។)



# អំពីធ្នាក់

## (Preposition)

**ធ្នាក់** (Preposition) គឺជាពាក្យសំរាប់ប្រើជាមួយ នាម ឬសព្វនាមដើម្បីបង្ហាញថា តើនាមឬសព្វនាមនោះ ជាប់ទាក់ទងនឹងពាក្យដទៃទៀតក្នុងល្បះដូចម្តេច ។ ធ្នាក់តែងបង្ហាញប្រាប់: ទិសដៅ ទីតាំង ឬទាក់ទងនឹងពេលវេលា ។

ធ្នាក់មានពាក្យដូចជា: *ជិត , ក្បែរ , ក្រៅ , ក្នុង , នៅ , អំពី , ជាមួយ, នៃ តាម , យោងតាម , ប្រឈមនឹង , ជំនួសដោយ , ដោយគ្មាន , ដោយសារ , លើ , ក្រោម* ........... ជាដើម ។

**១.ធ្នាក់កន្លែង** (Preposition of Place ) គឺជាធ្នាក់សំរាប់ប្រាប់ ពីទីកន្លែង ឬទិសដៅនៃនាម ។

-មនុស្សខ្លះ នៅ**ខាងក្នុង** ភោជនីដ្ឋាន ។

-ពិសិដ្ឋ កំពុងរង់ចាំ **ខាងក្រៅ** ភោជនីដ្ឋាន ។

-រូបថតមួយ នៅ**ខាងលើ** តុ ។

-មានឆ្កែមួយ នៅ**ក្រោម** តុ ។

-រថយន្ត កំពុងបើក**ឆ្ពោះទៅ** ខេត្តកំពង់ចាម ។

-រតនា អង្គុយ**បន្ទាប់ពី** រស្មី ។

-រថយន្តក្រុង នៅ**ខាងមុខ** រថយន្តដឹកទំនិញ ។

-ដានី ដើរតាម ផ្លូវនរោត្តម ។

ធ្នាក់កន្លែងមានពាក្យដូចជា : *ក្នុង , ខាងក្នុង , ក្រៅ , ខាងក្រៅ , លើ , ខាងលើ , ខាងលើនៃ , ក្រៅ , ខាងក្រោម , ឆ្លងកាត់ , ខាងក្រៅនៃ , នៅឯ , ឯពី , ឆ្ពោះឆ្ងាយពី , ឆ្ពោះត្រង់ , បន្ទាប់ , បន្ទាប់ពី , ជិត , ខាងមុខ , ខាងក្រោយ ទល់មុខ , ក្នុងចំណោម , ជុំវិញ , ឯនាយ , កាត់តាម , តាមបណ្តោយ , រវាង ជាមួយ , នឹងជាមួយ.....* ។

**២.ធ្នាក់កាល** (Preposition of Time) គឺជាធ្នាក់សំរាប់ប្រាប់ ពីកាលកំណត់ នៃពេលវេលាណាមួយ ។

-ខ្ញុំនឹងទៅជួបឯង **នៅម៉ោង២រសៀល** ។

-គាត់ មក**នៅខែកុម្ភៈ** ។

-ពួកគេ ណាត់ជួបគ្នា **នៅថ្ងៃទី៣ខែមករានេះ** ។

-ខ្ញុំបានទទួលសំបុត្រនេះ **កាលពី** ថ្ងៃសៅរ៍ ។

-អ្នកអាចប្រលងម្តងទៀត **ឆ្នាំក្រោយ** ។

-គ្មានមន្ត្រីរាជការណាម្នាក់ធ្វើការទេ **ក្នុងអំឡុង** ថ្ងៃបុណ្យអុំទូក ។

-**អំឡុង** មួយសប្តាហ៍ ថ្ងៃបុណ្យអុំទូក គ្មានមន្ត្រីណាម្នាក់ធ្វើការទេ ។

-នាងចង់សំរាក **រយៈពេល** មួយសប្តាហ៍ ។

-គាត់រស់នៅ **តាំងពី** ឆ្នាំ១៩៩០ ម្លេះ ។

-ខ្ញុំរស់នៅទីនេះ ១០ឆ្នាំ **កន្លងទៅហើយ** ។

-កាលដប់ឆ្នាំមុន នាងរស់នៅខេត្តព្រៃវែង ។

-គាត់ធ្វើការ **រហូតដល់** ម៉ោង១២ថ្ងៃត្រង់ ។

-សំបុត្រត្រូវដាក់លក់ **ចាប់ពី** សប្តាហ៍នេះហើយ ។

-មនុស្សមិនធ្វើការទេ **ក្នុងរវាង** បុណ្យចូលឆ្នាំនិងបុណ្យភ្ជុំបិណ្ឌ ។

-ធ្នាក់កាលមានដូចជា : *នៅ , កាលពី , ឆ្នាំក្រោយ , ឆ្នាំមុន , ចាប់ពី រហូតដល់ , ក្នុងរវាង* ........ ។

## ៣.ធ្នាក់មានន័យដូចជាឈ្នាប់:

-យើងជំទាស់ **នឹង** ការធ្វើដំណើរនោះពីព្រោះអាកាសធាតុមិនល្អ ។

-យើងធ្វើដំណើរ **តាម** យន្តហោះ ។

-គាត់និយាយ **ដូចជា** អ្នកឯកទេស ។

## ៤.កម្មបទរបស់ធ្នាក់ (The object of The preposition )

នាមឬសព្វនាម ដែលនៅបន្ទាប់ពីធ្នាក់ក្នុងល្បះគេហៅថា **កម្មបទរបស់ធ្នាក់** ។

ឧ.រថយន្ត បានបើកបុក **នឹងរថភ្លើង** ហើយមនុស្ស បានលោត **ចេញពី រថយន្ត** ។

នៅក្នុងឧទាហរណ៍ខាងលើធ្នាក់ "នឹង , ចេញពី" បង្ហាញពីទំនាក់ទំនង រវាង "**បានបើកបុកនឹងរថភ្លើង , និងបានលោតចេញនឹងរថយន្ត**" ។

# អំពីឈ្នាប់

Conjuntion

**ឈ្នាប់** (Conjuntion) គឺជាពាក្យដែលសំរាប់ភ្ជាប់ពាក្យ និងពាក្យ ឬក្រុមពាក្យ និងពាក្យ ឬបង្ហាញពីទំនាក់ទំនងឃ្លានិងឃ្លា ។ ឈ្នាប់អាចផ្លាស់ប្តូរល្បះខ្លីមួយ អោយវែងបាននិងអាចផ្តួបល្បះ ឬឃ្លា ចូលគ្នាបានផងដែរ ។

ឈ្នាប់មានដូចជាៈ *និង , ឬ , ប៉ុន្តែ , ដូច្នេះ , ពីព្រោះ , ប្រសិនបើហើយ និង..... ។*

**ទីតាំងរបស់ឈ្នាប់:** -ឈ្នាប់ភ្ជាប់ពាក្យ នៅក្នុងល្បះ ។

ឧ. ខ្ញុំ ទិញ ត្រី **និង** បន្លែ ។

-ឈ្នាប់ចងភ្ជាប់ឃ្លា និងឃ្លា ។

ឧ. វា ចូលចិត្តលេងកីឡា តែវាមិនចូលចិត្តសិល្បៈទេ ។

**១.ឈ្នាប់ចង** (Coordinating Conjunction) គឺជាឈ្នាប់សំរាប់ភ្ជាប់ពាក្យ និងពាក្យឬក្រុមពាក្យ និងពាក្យ ។

ឈ្នាប់ចងមានដូចជាៈ*និង , ប៉ុន្តែ , ឬ , សំរាប់ , នៅឡើយ , ដូច្នេះ ឯ ហើយ , ហើយនិង.. ។*

ឧ សុធារី ចេះពីរបៀបធ្វើអន្សម ប៉ុន្តែខ្ញុំចេះពីរបៀបស្លសម្លកកូរ ។

ឧ. ខ្ញុំ មានឡានពីរ ឯគាត់មានម៉ូតូមួយ ។

ឧ. ហុចញញួរ និងដែកគោល ឲ្យខ្ញុំបន្តិច ។

ឧ. យើងទុកវា នៅចន្លោះធុងទឹកក្តៅ **និង** ប៉ាន់តែ ។

**២.ឈ្នាប់ឃ្លា** (Subordinating Conjunction) គឺជាឈ្នាប់បង្ហាញប្រាប់ពីការទាក់ទងឃ្លា និងឃ្លា(ឃ្លាពីរ) ។ ប៉ុន្តែឃ្លាទាំងពីរនោះ មានឃ្លាមួយជាឃ្លាច្បង ហើយឃ្លាមួយទៀតជាឃ្លារណប ដែលសំរាប់បញ្ជាក់ន័យអោយទៅឃ្លាច្បង ។ ឃ្លាទាំងពីរនេះ មានន័យទាក់ទងទៅនឹងៈ **ពេលវេលា ,របៀបបទហេតុ ឬលទ្ធផល** រវាងឃ្លា និងឃ្លា ។

ឃ្លារណប វាបង្ហាញអោយឃើញតាមរយៈឈ្នាប់ឃ្លា ។ ភាគច្រើនវាមានកន្សោមគុ. កិ ។

**ឈ្នាប់ឃ្លាធម្មតាមានដូចជា:**

*បន្ទាប់មក , ពីមុន , ដូចជា , នៅតែ , ទោះបី , ប្រសិន , ប្រសិនបើ យ៉ាងហោច , ត្រឹមតែ , ដូច្នោះ , ដូច្នេះ, រហូតដល់ , ពីព្រោះ , តាំងពី , ខណៈពេល ពេលណាក៏ដោយ , តាំងពីពេលនោះ ..... ។*

ឧ. បើសិន អ្នកចង់ចេះភាសាអង់គ្លេស អ្នកត្រូវតែរៀន ។

ឧ. កុំយកឯកសារតាមខ្លួន ពីព្រោះការប្រលងតឹងតែងណាស់ ។

**សូមចងចាំថា** ការដាក់ឈ្នាប់នៅដើមឃ្លា ធ្វើអោយឃ្លានោះ ហាក់ដូចជាល្បះមួយផងដែរ ។

ឧ. ប្រសិនបើ អ្នកចង់ចេះភាសាអង់គ្លេស ។

ឧ. ទោះបី អ្នកមកវិញ ។ (អ្នកនៅតែជាសមាជិករបស់យើង)

# អំពីឧទានសព្ទ

## (Interjection)

**ឧទានសព្ទ** (Interjection) គឺជាពាក្យឬក្រុមពាក្យ ដែលអ្នកនិយាយបន្លឺសូររបស់វាឡើងឮខ្លាំង ខុសប្លែកពីពាក្យធម្មតាដើម្បីបង្ហាញពីអារម្មណ៍ ភ្ញាក់ផ្អើល ,បង្ហាញពីការរំជួលចិត្ត របស់អ្នកនិយាយ ។

ឧទានសព្ទមានដូចជា : *អូ ,អ្ហេ ,អ្ហ៎ា ,អីយ៉ា ,នែ ,យី , អូយ ,អើ ណែណេះ ,នុ៎ះ ,នោះន៎ ,ម៉ាច់ហើយ ,អស្ចារ្យ ,ចំមែន ,ចុំ ,ហ៊ឺស យើសណ្ហើយ .....* ។

### *ក.ឧទានសព្ទគ្រាប់សូរ បាតុភូតធម្មជាតិ*

- ផ្គរលាន់ គ្រឹម! គ្រឹម!
- ខ្យល់បក់ វូៗ !
- រន្ទះបាញ់ ផាំង!
- សមុទ្ររលក គ្រាំៗ !

### *ខ.ឧទានសព្ទគ្រាប់សូរ សំរែកសត្វ*

- ឆ្កែព្រួស វ៉ូសៗ!
- សត្វត្លុម តុំៗ !តុំ.. !
- ចង្រិតយំ ច្រេតៗ!

## គ.ឧទានសព្ទគ្រាប់សូរវត្ថុ

-ខ្យល់វាយបង្អួច ព្ឃផាំង!

-សូរស៊ីរ៉ែនឡានពេទ្យ វ៉ូវ៉ៅៗ !



មនុស្សល្ងង់មិនអាចធ្វើចេះបានទេ តែអ្នកចេះអាចធ្វើល្ងង់បាន ដោយងាយបំផុត ។

# អំពីល្បះ

( Sentence)

**ល្បះ** (Sentence) គឺជាពាក្យមួយក្រុម ដែលបង្ហាញពីគំនិតមួយពេញលេញ មានន័យស្តាប់បាន ។ វាអាចបង្កើត នូវសេចក្តីរាយការណ៍ អំពីអ្វីមួយ , និងអាចសួរ ឬប្រាប់នណាម្នាក់ អំពីរឿងអ្វីមួយ , ហើយនិងអាចបង្ហាញពីមនោសញ្ចេតនាថែមទៀតផង ។

**I.បែបនៃល្បះ** (Kinds of Sentence)

**១.ល្បះបញ្ជាក់** (Declarative Sentence) គឺជាល្បះរាយការណ៍ ។

ឧ. ក្មេងក្នុងភូមិខ្ញុំ ទៅរៀនគ្រប់ៗគ្នា ។(ល្បះបញ្ជាក់ស្រប)

ឧ. ក្មេងក្នុងភូមិខ្ញុំ មិនទៅរៀនគ្រប់ៗគ្នាទេ ។(ល្បះបញ្ជាក់បដិសេធន៍)

☞ សញ្ញាបញ្ចប់*ល្បះបញ្ជាក់*គឺ " ។ "

**២.ល្បះសំនួរ** (Intrrogative Sentence) គឺជាល្បះសំរាប់សួរ ។

ឧ. តើអ្នក ស្គាល់សុជាទេ?(ល្បះសំនួរស្រប)

ឧ. តើអ្នក មិនស្គាល់សុជាទេឬ?(ល្បះសំនួរបដិសេធន៍)

☞ សញ្ញាបញ្ចប់*ល្បះសំនួរ*គឺ " ? "

**៣.ល្បះបញ្ជា** (Imperative Sentence) គឺជាល្បះសំរាប់ធ្វើសំនូមពរឬបញ្ជានរណាម្នាក់អោយធ្វើអ្វីមួយ ។

ឧ. សុខ បើកបង្អួចនោះផង ។(ល្បះបញ្ជាស្រប)

ឧ. សុខ កុំបើកបង្អួចនោះអី ។(ល្បះបញ្ជាបដិសេធន៍)

☞ សញ្ញាបញ្ចប់*ល្បះបញ្ហា* គឺ " ។ ឬ ! "

**៤.ល្បះឧទាន**(Exclamatory Sentence) គឺជាល្បះសំរាប់បង្ហាញនូវការភ្ញាក់ផ្អើល ។

ឧ. យី! មក៍ !(ល្បះឧទានស្រប)

ឧ. កុំមក៍ ! (ល្បះឧទានបដិសេធន៍)

☞ សញ្ញាបញ្ចប់*ល្បះឧទាន* គឺ " ! "

កំ. សំ. ល្បះទាំងបួននេះអាចជាៈល្បះស្រប ឬល្បះបដិសេធន៍បានដូចគ្នា ។

**II.ប្រភេទនៃល្បះ** (Sentence Types)

គ្រប់ល្បះទាំងអស់ តែងតែមានពីរផ្នែក ។ ផ្នែកទី១ប្រាប់ " នរណា ឬអ្វី " ដែលល្បះនិយាយ ។ នោះគឺជា " ប្រធាន " ។ ផ្នែកទី២ប្រាប់រឿងអ្វីមួយ អំពីប្រធាន ។ នោះគឺជា " កន្សោមកិរិយា " ។

ប្រធាននិងកន្សោមកិរិយា អាចខ្លីឬវែងអាស្រ័យព័តមានតិចឬច្រើន ។

| ប្រធាន(នរណា/ អ្វី) | ក. កិ(**អ្វីដែលនិយាយពីប្រធាន**) |
|---|---|
| សិស្ស | ធ្វើពលកម្មនៅក្នុងសាលា ។ |
| កសិករភូមិខ្ញុំ | កំពុងច្រូតកាត់ស្រូវប្រាំង ។ |
| ប្រជាពលរដ្ឋរងគ្រោះ | បានមកទទួលអំណោយពីសម្ដេចឪ ។ |

វិធីមួយដើម្បីយល់ផ្នែកនីមួយៗនៃល្បះ គឺត្រូវគិតថាល្បះកំពុងនិយាយពីនរណាធ្វើអ្វី ឬអ្វីកើតឡើង ។ ប្រធានប្រាប់ (នរណា/ អ្វី) ។ កិរិយាប្រាប់(អ្វីត្រូវធ្វើ ឬអ្វីកើតឡើង) ។

**១.ល្បះទោល** (Simple Sentence ) គឺជាល្បះដែលមានតែកន្សោមប្រធានមួយ និងកន្សោមកិរិយាមួយប៉ុណ្ណោះ ។

ទំរង់ទី១

១. ប្រ. + កិ.អ

ឧ. ក្មេង យំ ។
ប្រ. កិ.អ

២. ប្រ. + កិ.អ + គុ.កិ

ឧ. ក្មេង យំ យ៉ាងខ្លាំង ។
ប្រ. កិ.អ គុ.កិ

៣. ប្រ. + កិ.ស + កម្ម
ប្រ. + កិ.ស + កម្ម + ធ + កម្ម

ឧ. កសិករ ច្រូត ស្រូវ ។
ប្រ. កិ.ស កម្ម

ឧ. គាត់ អោយ ប៊ិច ដល់ សុភាព ។
ប្រ. កិ.ស កម្ម ធ កម្ម

៤. ប្រ.+ កិ.អ + ធ + កម្ម

ឧ. ពិសិដ្ឋ អង្គុយ លើ ម៉ូតូ ។
ប្រ. កិ.អ ធ កម្ម

៥. ប្រ.+ កិ.ស + ក.កម្ម

ឧ. ពិសី ទិញ បន្លែនិងត្រី ។
ប្រ. កិ.ស ក.កម្ម

១. ក.ប្រ. + កិ.អ

ឧ. ក្មេងៗ យំ ។
ប្រ. កិ.អ

២. ក.ប្រ. + កិ.អ + គុ.កិ

ឧ. សិស្សានុសិស្ស រាំ ស្អាតណាស់ ។
ប្រ. កិ.អ គុ.កិ

ទំរង់ទី២

៣. ក. ប្រ + កិ. ស + កម្ម

ឧ. ក្រុមបាតុករ ផុត កង់ឡាន ។
ប្រ. កិ. ស កម្ម

៤. ក. ប្រ. + កិ. អ + ធ + កម្ម

ឧ. ក្រុមបាតុករ ដើរ តាម វិថីនារុ ។
ក. ប្រ. កិ. អ ធ កម្ម

៥. ក. ប្រ. + កិ. ស + ក. កម្ម

ឧ. ធារីនិងធីតា ទិញ ប៊ិចនិងបន្ទាត់ ។
ក. ប្រ. កិ. អ ក. កម្ម

ទំរង់ទី៣

១. ក-ប្រ. / ខ-ក. ប្រ } + ក. កិ. អ

ឧ. សុផា ចង់ច្រៀង ។
ប្រ. ក. កិ. អ

ឧ. សុផានិងសុភី ចូលចិត្តរៀន ។
ក. ប្រ ក. កិ. អ

២. ក-ប្រ. / ខ-ក. ប្រ } + ក. កិ. អ + គុ. កិ

ឧ. សុផា ចង់ច្រៀង ណាស់ ។
ប្រ. ក. កិ. អ គុ. កិ

ឧ. សុផានិងសុភី ចូលចិត្តរៀន ណាស់ ។
ក. ប្រ ក. កិ. អ គុ. កិ

៣. ក-ប្រ. / ខ-ក. ប្រ } + ក. កិ. ស + កម្ម

ឧ. សុផា ចង់ជួប សុភាព ។
ប្រ. ក. កិ. ស កម្ម

ឧ. សុផានិងសុភី ចូលចិត្តរៀន ភាសាខ្មែរ ។
ក. ប្រ ក. កិ. ស កម្ម

**២.ល្បះផ្សំ** (Complex Sentence) គឺជាល្បះដែលមានឃ្លាចម្បងមួយ និងមានឃ្លារណប ចាប់ពីមួយឡើងទៅ ។***ឃ្លាចម្បង***(Principal Clause) គឺជាឃ្លាមួយដែល អាចឈរនៅតែឯងបាន និងមានន័យគ្រប់គ្រាន់ (វាជាឃ្លាឯករាជ "Independent Clause") ។***ឃ្លារណប***(Subordinate Clause) គឺជាឃ្លាមួយដែលមិនអាចឈរនៅតែឯងបានទេ និងពុំទាន់មានន័យគ្រាប់គ្រាន់ឡើយ(វាជាឃ្លាពឹងពាក់លើឃ្លាចម្បង"Dependent Clause") ។

**ឃ្លាចម្បង និងឃ្លារណប** សុទ្ធតែមានប្រធាន កិរិយា ឬកម្មបទដូចគ្នា។ ឃ្លារណបអាចនៅបន្ទាប់ពីឃ្លាចម្បង ឬនៅដើមឃ្លាក៏បាន ។ មើលឧ.១ ។

ឃ្លាចម្បង ឃ្លារណប

ក- ប្រ.+ កិ + កម្ម + ឈ្នាប់ + ប្រ. + កិ + កម្ម

ឃ្លារណប ឃ្លាចម្បង

ខ- ឈ្នាប់ + ប្រ.+ កិ + កម្ម + ប្រ. + កិ + កម្ម

ឃ្លាចម្បង ឃ្លារណប

ឧ១. គេ បានជូន គាត់ទៅផ្ទះ បន្ទាប់ពី គាត់ បញ្ចប់ ការងារ ។

ប្រ. កិ. កម្ម. ឈ. ប្រ. កិ. កម្ម.

ឃ្លារណប ឃ្លាចម្បង

- បន្ទាប់ពី គាត់ បញ្ចប់ ការងារ គេ បានជូន គាត់ទៅផ្ទះ ។

ឈ. ប្រ. កិ. កម្ម. ប្រ. កិ. កម្ម.

ឃ្លារណប ឃ្លាចម្បង

-ប្រសិនបើ គាត់ ឈ្នះ កីឡាករថៃ ស៊ីថន ទទួល មេដាយមាស ។

ឈ. ប្រ. កិ. កម្ម ប្រ. កិ. កម្ម.

ឃ្លាចម្បង ឃ្លារណប

-ស៊ីថន ទទួល មេដាយមាស ប្រសិនបើ គាត់ ឈ្នះ កីឡាករថៃ ។

ប្រ. កិ. កម្ម. ឈ. ប្រ. កិ. កម្ម.

នៅក្នុងឧទាហរណ៍ទី២ខាងក្រោមនេះ ឃ្លារណបមិនអាចយកទៅដាក់ធ្វើជាឃ្លាដើមបានឡើយ គឺវាស្ថិតនៅបន្ទាប់ឃ្លាចម្បងតែប៉ុណ្ណោះ ។

ឃ្លាចម្បង ឃ្លារណប

២២. ប៉ូលិស ចាប់ បុរសម្នាក់ {ព្រោះ / ដែល / ដោយ} គេ គិតថា គាត់ ជា ចោរ ។

ប្រ. កិ. កម្ម. ឈ. ប្រ. កិ. កម្ម.

ឃ្លាចម្បង ឃ្លារណប

-តើអ្នក ស្គាល់ សណ្ឋាគារ ដែលយើង ស្នាក់នៅទេ?

ប្រ. កិ. កម្ម. ឈ. ប្រ. កិ.

ឃ្លាចម្បង ឃ្លារណប

-តើអ្នក ស្គាល់ សណ្ឋាគារ (ដែល)យើងស្នាក់នៅទេ?

ប្រ. កិ. កម្ម. ឈ. ប្រ. កិ.

**៣.ល្បះក្រង** (Compound Sentence) គឺកើតឡើងដោយល្បះទោលរួមផ្សំគ្នា ចាប់ពីពីរឡើងទៅ ។ បើល្បះក្រងកើតឡើងដោយសារតែល្បះពីរ គេប្រើ "ឈ្នាប់ចង" ។ ហើយបើល្បះក្រងកើតឡើងដោយមានល្បះទោលច្រើនរួមគ្នា គេត្រូវដាក់ល្បះទាំងនោះបន្តបន្ទាប់គ្នាតែម្តង គឺមិនបាច់ប្រើ "ឈ្នាប់ចង" ឡើយ ។

| ល្បះទី១ | ឈ្នាប់ចង | ល្បះទី២ |
|---|---|---|
| ឧ. គាត់មានគោមួយ | ចំណែក | នាង មានក្របីមួយ ។ |
| - គាត់ជាកសិករ | ប៉ុន្តែ | គាត់ចូលចិត្តអានកាសែត ។ |
| - សុផលចូលចិត្តរៀន | តែ | វាមិនចូលចិត្តកីឡាទេ ។ |

ខាងលើនេះជាល្បះក្រង ដែលគេតែងឡើងដោយប្រើ "ឈ្នាប់ចង" ។ ឯខាងក្រោមនេះវិញជាល្បះក្រង ដែលគេតែងឡើងដោយដាក់ល្បះបន្តគ្នា គឺមិនចាំបាច់ប្រើឈ្នាប់ចងឡើយ ។

ឧ. ផ្លែព្រួស ជ្រូកស្រែក ក្មេងយំ ពេញភូមិ ។

**៤.ល្បះផ្សំក្រង** (Compound-complex Sentence) គឺកើតឡើងដោយសារការរួមបញ្ចូលគ្នារវាងល្បះផ្សំនិងល្បះផ្សំ ។

គាត់ វាយ គោ ព្រោះ វា ស៊ី ស្រូវ ហើយ ឥឡូវវា មិនស៊ី ស្រូវទេដោយ គាត់ ចង វា ។

[ប្រ. + កិ. + កម្ម. + ឈ. យ + ប្រ. + កិ. + កម្ម.] + [ឈ. ច] + [ប្រ. + កិ. + កម្ម. + ឈ. យ + ប្រ. + កិ. + កម្ម.]

ឃ្លាចម្បង ឃ្លារណប

ឧ. ឧចត្រូវបានចាប់ខ្លួន ពីព្រោះ វាជាប់ពាក់ព័ន្ធការលក់គ្រឿងញៀន

ឈ. ច ឃ្លាចម្បង ឃ្លារណប

ហើយ វាអាចកាត់ទោសប្រហារជីវិត ប្រសិនបើ តុលាការរកឃើញ

ភស្តុតាងពិតប្រាកដមែន ។

## III.ល្បះកត្តុនិងល្បះកម្ម (Active Sentence and Passive Sentence)

**១.ល្បះកត្តុ** (Active Sentence) គឺជាល្បះដែលប្រធានធ្វើអំពើ ហើយកម្មបទជាអ្នកទទួលរងអំពើ(ល្បះប្រភេទនេះ ប្រើប្រាស់យ៉ាងច្រើនបំផុតក្នុងទំនាក់ទំនងធម្មតា) ។

| ប្រធាន | កិរិយា | កម្មបទ | |
|---|---|---|---|
| ឧ. រស្មី | សរសេរ | សំបុត្រ ។ | ក្នុងឧទាហរណ៍ទាំងនេះ ប្រធានជាអ្នកធ្វើអំពើ រីឯកម្មបទជាអ្នកទទួលរងនូវអំពើ ពីប្រធាន ។ |
| - នាង | ផ្ញើ | សំបុត្រ ។ | |
| - គ្រូ | កែ | កិច្ចការសិស្ស ។ | |
| - ភ្លើង | ឆេះ | ផ្ទះគាត់ ។ | |

**២.ល្បះកម្ម** (Passive Sentence) គឺជាល្បះដែលប្រធានទទួលរងនូវអំពើ ចំណែកកម្មបទជាអ្នកធ្វើអំពើ ។ ល្បះកម្មប្រាប់អ្វីដែលត្រូវធ្វើទៅលើប្រធាន ។ កិរិយាប្រើនៅក្នុងល្បះកម្ម តែងតែជា**កិរិយាសកម្ម** ឯកិរិយាអកម្មមិនអាចប្រើបានឡើយ ។

<table>
<tr><th>ប្រធាន</th><th>កិរិយា</th><th>កម្មបទ</th><th></th></tr>
<tr><td>ឧ. សំបុត្រ</td><td>ត្រូវបានសរសេរដោយ</td><td>រស្មី ។</td><td rowspan="8">ក្នុងឧទាហរណ៍ទាំងនេះ ប្រធានជាអ្នករងនូវអំពើ ឯកម្មបទជាអ្នកធ្វើអំពើ ។ គេអាចសរសេរល្បះកម្មបានពីរបែប ទី១ប្រើពាក្យ “ដោយ”ទី២ដោយមិនប្រើពាក្យ“ដោយ”ទេ ។ ម្យ៉ាងទៀតល្បះប្រភេទនេះខ្មែរយើងមិនសូវប្រើច្រើនណាស់ទេ ។</td></tr>
<tr><td>+ សំបុត្រ</td><td>ត្រូវបានរស្មីសរសេរ ។</td><td></td></tr>
<tr><td>- សំបុត្រ</td><td>ត្រូវបានផ្ញើ ដោយ</td><td>នាង ។</td></tr>
<tr><td>+ សំបុត្រ</td><td>ត្រូវបាននាងផ្ញើ ។</td><td></td></tr>
<tr><td>- កិច្ចការសិស្ស</td><td>ត្រូវបានកែ ដោយ</td><td>គ្រូ ។</td></tr>
<tr><td>+ កិច្ចការសិស្ស</td><td>ត្រូវបានគ្រូកែ ។</td><td></td></tr>
<tr><td>- ផ្ទះគាត់</td><td>ត្រូវបានឆេះ ដោយ</td><td>ភ្លើង ។</td></tr>
<tr><td>+ ផ្ទះគាត់</td><td>ត្រូវបានភ្លើងឆេះ ។</td><td></td></tr>
</table>

| | |
|---|---|
| ប្រ. កិ. កម្ម.<br>រស្មី សរសេរ សំបុត្រ ។ | ល្បះកត្តុ |
| សំបុត្រ ត្រូវបានសរសេរ ដោយរស្មី ។<br>ប្រ. កិ. កម្ម. | ល្បះកម្ម |

ដើម្បីប្តូរល្បះកត្តុទៅល្បះកម្ម គេយកកម្មបទពីល្បះកត្តុទៅធ្វើជាប្រធាននៃល្បះកម្ម ឯប្រធាននៅក្នុងល្បះកត្តុធ្វើជាកម្មបទនៃល្បះកម្មវិញ ។

# អំពីកន្សោមពាក្យ
## (Phrase)

កន្សោមពាក្យ (Phrase) គឺជាកំរងពាក្យដែលទំនាក់ទនងគ្នា ហើយមិនរួមបញ្ចូលប្រធានឬកិរិយាឡើយ ។

**១.កន្សោមនាម** (Noun Phrase) គឺនាមមួយរួមជាមួយ ពាក្យបញ្ជាក់របស់វាមួយចំនួនទៀត ។ កន្សោមនាមមានដូចជាៈ

ផ្ទះក្បឿងម៉ូតបូរាណ , រថយន្តកង់ដប់ពីណាក្រហមចង្កូតឆ្វេង.. ។

ឧ. ***រថយន្តកង់ដប់ពីណាក្រហមចង្កូតឆ្វេង*** ជារបស់តាម៉ៅ ។

- គាត់ស្រលាញ់ ***ផ្ទះក្បឿងម៉ូតបូរាណ*** ។

**២.កន្សោមកិរិយា** (Verb Phrase) គឺជាកិរិយាមួយក្រុមដែលមានទំនាក់ទំនងគ្នា ហើយវាហាក់រួមគ្នាផ្ដល់ន័យអោយកិរិយាណាមួយជាកិរិយាសំខាន់ជាងគេ ។ កន្សោមកិរិយាមានដូចជាៈ

ចង់ទៅពិនិត្យមើល , ព្យាយាមចូលជួយសង្គ្រោះ... ។

ឧ. លោកប្រធានាធិបតី ***ចង់ទៅពិនិត្យមើល*** កសិដ្ឋានវិទ្យាសាស្ត្រនោះ ។

- ប៉ូលិស ***ព្យាយាមចូលជួយសង្គ្រោះ*** កម្មករពីគំនរបាក់បែក ។

**៣.កន្សោមគុណនាម** (Adjective Phrase) គឺជាគុណនាមមួយក្រុមដែលរួមគ្នាបញ្ជាក់ន័យអោយ នាមមួយ ឬសព្វនាមមួយ ។ កន្សោមគុណ-

នាមរួមមានៈ

ធំថ្មីមួយ ,ស ស្ដើង ,.... ។

ឧ. គាត់ទិញបាន ផ្ទះ***ធំថ្មីមួយ*** ។

**៤.កន្សោមធ្នាក់** (Preposition Phrase )គឺមានធ្នាក់មួយរួមនិងកម្មបទរបស់វាមួយចំនួនទៀត ។ កន្សោមនាមធ្នាក់មានដូចជាៈ

ជាមួយស្វាយជ្រក់ ,តាមមាត់ទន្លេ... ។

ឧ. គាត់ចូលចិត្តហូបត្រីអាំង ***ជាមួយស្វាយជ្រក់*** ។

– នាងចូលចិត្តដើរកំសាន្ត ***តាមមាត់ទន្លេ*** ។

## អំពីប្រភេទឃ្លា
## (Clause)

ដែលហៅថាឃ្លា គឺមានទាំងប្រធាននិងកិរិយា បូករួមជាមួយពាក្យបញ្ចាក់របស់វាមួយចំនួនទៀត ។ ប្រភេទឃ្លាសំខាន់ៗមានពីរ គឺឃ្លាច្បង (Independent Clause ) និងឃ្លារណប (Dependent Clause ) ។

**១.ឃ្លាច្បង** (Independent Clause )គឺជាល្បះពេញលេញមួយ ។

ប្រ. + កិ.

ឧ. ក្មេង យំ ។

ប្រ. + កិ. + ធាតុបង្គ្រប់(កម្មបទ ,គុ. កិ ,កន្សោមមានធ្នាក់)

ឧ. នាង ស្រោច ផ្កា ។

-ឪពុកនាង អោយ នាង សៀវភៅមួយ ។

**២.ឃ្លារណប** (Dependent Clause) គឺពុំទាន់មានលក្ខណៈជាល្បះពេញលេញមួយទេ វាពឹងពាក់លើឃ្លាមួយទៀតដើម្បីបំពេញន័យអោយវា គឺឃ្លាច្បង ។ ការដែលធ្វើអោយយើង ស្គាល់ឃ្លាមួយថាជាឃ្លារណបបាន គឺដោយសារឃ្លានោះ មានប្រើឈ្នាប់ឃ្លា (បន្ទាប់ពី, តាំងពី) ឬសព្វនាមឈ្នាប់ ។

ឧ. គាត់ ផឹក តែ ។ (ឃ្លាច្បង)

-តាំងពី គាត់ ផឹក តែ ។ (ឃ្លារណប)

ដែលគាត់ ផឹក តែ ។(ឃ្លារណប)

បន្ទាប់ពី គាត់ ផឹក តែ ។(ឃ្លារណប)

ឃ្លារណបដូចជាកន្សោមពាក្យដែរ វាដើរតួជាថ្នាក់ពាក្យមួយ ក្នុងល្បះ ។ ឃ្លារណបអាចមានមុខងារ ជា នាម , គុណនាម , ឬគុ. កិ ។

ក. ឃ្លានាម(Noun Clause) គឺជាឃ្លារណបមួយ ដែលមានមុខងារដូចជានាមមួយដែរ ។ វាជាឃ្លា ឈរជំនួសអោយនាម ឬសព្វនាមមួយ នៅក្នុងល្បះ ។

ឧ. អ្វីដែលលោកប្រាប់ខ្ញុំ នឹងមិនមានគេដឹងឡើយ ។

-នរណាម្នាក់ ហូប ផ្លែចេកនោះពិតជាពុល ។

លំហាត់:

រកឃ្លានាម នៅក្នុងល្បះនីមួយៗខាងក្រោមនេះ ។ គូសបន្ទាត់ពីក្រោមឃ្លានាម រួចបញ្ជាក់ថា ឃ្លានាមនោះមានមុខងារជាៈប្រ., កម្មបទផ្ទាល់ , កម្មបទមិនផ្ទាល់ , កម្មបទរបស់ធ្នាក់ ។

១. ខ្ញុំ ចាំ អ្វីដែលលោកប្រាប់ខ្ញុំ ។

២. វិធីដែលគាត់ទទួលយក គឺជាការជំទាស់ដ៏ធំមួយរបស់នាង ។

៣. ធីតា បានសួរ ពេលណានាង អាចចេញទៅបាន ។

៤. ខ្ញុំ ដឹង នរណាជាអ្នកធ្វើបែកកញ្ចក់ ។

ខ. ឃ្លាគុណនាម(Adjtive Clause)គឺត្រូវបានបង្ហាញដោយសព្វនាមឈ្នាប់ (ដែល)ហើយវានៅបន្ទាប់ពីនាមឬសព្វនាម ដែលវាបញ្ជាក់ន័យអោយ ។ វាជាឃ្លា ឈរជំនួសអោយគុណនាម ហើយមាននាទីដូចជាគុណនាមដែរ គឺវាបញ្ជាក់លក្ខណៈអោយនាម ឬសព្វនាមនៅក្នុងល្បះ ។

ឧ. លោកគ្រូ ដែលពាក់អាវផ្ទៃមេឃ គឺជានាយកសាលា ។

- នាង ស្រលាញ់ ហូលដែលនាំមកពីខេត្តព្រៃវែង ។

គ. ឃ្លាគុណកិរិយា(Adverb Clause)គឺដូចជាគុ. កិមួយដែរ ឃ្លាគុណកិរិយាត្រូវឆ្លើយនឹងសំនួរៈ ដូចម្តេច ? ពេលណា? ឯណា? ហេតុអ្វី? វាបញ្ជាក់ន័យអោយ កិរិយាសព្ទ , គុណនាម , គុណកិរិយាដទៃទៀត ។

២. ឪពុកម្ដាយនាង សប្បាយចិត្តណាស់ ពេលនាងបានប្រលងជាប់ ។

-បន្ទប់នេះគឺមានពន្លឺល្អ ដែលយើងអាចធ្វើការបាន ។

## ស្រីស្រស់ឆ្នើមឆ្នៃ

❁ស្រីស្រស់សម្ផស្សល្អត្រកាល ក្មេងខ្ចីពៅពាលទាំងសេចក្ដី
ឫកឆ្មើងដាក់អស់ប្រុសក្រក្រី ញញឹមប្រិមប្រិយដាក់អ្នកមាន។

❁រត់ហាច់ហែលហក់ខំហោះហើ រកអ្នកគ្រាន់បើនៅវិមាន
សម្បូរសម្បត្តិទ្រព្យធនធាន រឺឡាលុយឡានជាទ្រនំ។

❁បានមែនជួបចំដូចទំនាយ មានមេកន្ទាយជួយផ្សំផ្គុំ
ជួបចំប្រុសព្រានឃ្លានទឹកឃ្មុំ ស្រីស្រស់ក្រមុំលង់ទុក្ខា។

❁ទឹកស្ដាយចិត្តស្មោះប្រុសអ្នកក្រ លន់តួអង្វរសុំស្នេហា
ស្រលាញ់នាងពិតមិនមុសា ឥឡូវចិន្តាផ្កាអស់ក្លិន។



# អក្សរជ្រៀង

ក ខ គ ឃ ង   ច ឆ ជ ឈ ញ
្ក ្ខ ្គ ្ឃ ្ង   ្ច ្ឆ ្ជ ្ឈ ្ញ

ដ ឋ ឌ ឍ ណ   ត ថ ទ ធ ន
្ដ ្ឋ ្ឌ ្ឍ ្ណ   ្ត ្ថ ្ទ ្ធ ្ន

ប ផ ព ភ ម   យ រ ល វ ស
្ប ្ផ ្ព ្ភ ្ម   ្យ ្រ ្ល ្វ ្ស

ហ ឡ អ ៗ
្ហ ្ឡ ្អ

# អក្សរឈរ



ក្ក ខ្ខ គ្គ ឃ្ឃ ង្ង ច្ច ឆ្ឆ ជ្ជ ឈ្ឈ ញ្ញ

ដ្ដ ឋ្ឋ ឌ្ឌ ឍ្ឍ ណ្ណ ត្ត ថ្ថ ទ្ទ ធ្ធ ន្ន

ប្ប ផ្ផ ព្ព ភ្ភ ម្ម យ្យ រ្រ ល្ល វ្វ ស្ស

ហ្ហ ឡ អ្អ ។

# អក្សរខមមានជើង

ក្ក ខ្ខ គ្គ ឃ្ឃ ង្ង ច្ច ឆ្ឆ ជ្ជ ឈ្ឈ ញ្ញ

ដ្ដ ឋ្ឋ ឌ្ឌ ឍ្ឍ ណ្ណ ត្ត ថ្ថ ទ្ទ ធ្ធ ន្ន

ប្ប ផ្ផ ព្ព ភ្ភ ម្ម យ្យ រ្រ ល្ល វ្វ ស្ស

ហ្ហ ឡ អ្អ ។



# អក្សរមូលមានជើង

## សម័យបុរាណ

ក្ក ខ្ខ គ្គ ឃ្ឃ ង្ង ច្ច ឆ្ឆ ជ្ជ ឈ្ឈ ញ្ញ

ដ្ដ ឋ្ឋ ឌ្ឌ ឍ្ឍ ណ្ណ ត្ត ថ្ថ ទ្ទ ធ្ធ ន្ន

ប្ប ផ្ផ ព្ព ភ្ភ ម្ម យ្យ រ្រ ល្ល វ្វ ស្ស

ហ្ហ ឡ្ឡ អ្អ ។

# អក្សរខម

## មានស្រមោល

ក ខ គ ឃ ង ច ឆ ជ ឈ ញ

ដ ឋ ឌ ឍ ណ ត ថ ទ ធ ន

ប ផ ព ភ ម យ រ ល វ ស

ហ ឡ អ ៗ

អ អា ឥ ឦ ឧ ឩ ឫ ឬ ឭ ឮ ឯ ឰ

ឱ ឳ អុំ អំ អាំ អះ

# គំរូអក្សរក្បាច់

រចនាដោយ លោក ម៉ែន-អ៊ិញ និង លោក ឡូ-វៀន



១.

# អំពីគំនូសតាងល្បះ
(Diagram)

## ១.ល្បះទោល (Simple Sentence)

### ក.បែបទី១







### ខ.បែបទី២




តាងជាមែកធាង
ល
សព្. ប្រ
ក. កិ
កិ
ន
គាត់
ភ្ជួរ
ស្រែ ។
តាងជាប្រអប់
ក. កិ
ល
គាត់
ភ្ជួរ
ស្រែ ។
សព្. ប្រ
កិ
ន

## គ.បែបទី៣


តាងជាមែកធាង
ល
ក. ន. ប្រ
ក. កិ
កិ
ន
ឪពុកម្ដាយ
ទូន្មាន
កូន ។
តាងជាប្រអប់
ល
ក. កិ
ឪពុកម្ដាយ
ទូន្មាន
កូន ។
ក. ន. ប្រ
កិ
ន


តាងជាមែកធាង
ល
ក. សព្. ប្រ
ក. កិ
កិ
ន
នាងនិងគាត់
ទិញ
ផ្ទះថ្មី ។
តាងជាប្រអប់
ល
ក. កិ
នាងនិងគាត់
ទិញ
ផ្ទះថ្មី ។
ក. សព្. ប្រ
កិ
ន

## ឃ.បែបទី៤


តាងជាមែកធាង
ល
ន. ប្រ
ក. កិ
កិ
ក. ន
កមធ
ធ
ក. ន
ន
គុ
កសិករ
ស្ទូង
ស្រូវប្រាំង
ក្បែរ
ទន្លេ
តូច ។
តាងជាប្រអប់
ក. កិ
ធ
កមធ
ក. ន
ល
កសិករ
ស្ទូង
ស្រូវប្រាំង
ក្បែរ
ទន្លេ
តូច ។
ន. ប្រ
កិ
ក. ន
ន
គុ
តាងជាមែកធាង
ល
សព្វ. ប្រ
ក. កិ
កិ
ន
កមធ
ធ
ន
ពួកគេ
ដាំ
ផ្កា
ក្នុង
សួន ។


តាងជាប្រអប់
កិ
ន
កមធ
លស
ពួកគេ
ដាំ
ផ្កា
ក្នុង
សួន ។
សព្.ប្រ
ក. កិ
ធ
ន

## ង.បែបទី៥


តាងជាមែកធាង
លស
ក. នប្រ
ក. កិ
ន
កមធ
កិ
កមធ
ធ
ក. ន
ធ
ន
ន
គុ
បុរស
ក្នុង
ទូក
នោះ
លោតចូល
ក្នុង
ទឹក ។


តាងជាប្រអប់
ន
កមធ
ក. ន
ក. កិ
កមធ
លស
បុរស
ក្នុង
ទូក
នោះ
លោតចូល
ក្នុង
ទឹក ។
ក. នប្រ
ធ
ន
គុ
កិ
ធ
ន

២.ល្បះផ្សំ (Complex Sentence)

ក.បែបទី១



## ខ.បែបទី២


តាងជាមែកធាង(ក)
ឃ១
សព្.ប្រ
ក.កិ
កិ
ក.ន
ឃ.រណប
ឃ២
ឈ.ឃ្លា
ន.ប្រ
ក.កិ
កិ
ន
ប្រសិនបើ ស៊ីថន ឈ្នះ កីឡាករថៃ គាត់ ទទួល មេដាយមាស ។
តាងជាមែកធាង(ខ)
ឃ១
សព្.ប្រ
ក.កិ
កិ
ក.ន
ឃ.រណប
ឃ២
ឈ.ឃ្លា
ន.ប្រ
ក.កិ
កិ
ន
គាត់ ទទួល មេដាយមាស ប្រសិនបើ ស៊ីថន ឈ្នះ កីឡាករថៃ ។
តាងជាប្រអប់
ឃ១
កិ
ក.កិ
ឈ.ឃ្លា
ន.ប្រ
ក.កិ
គាត់
ទទួល
មេដាយមាស
ប្រសិនបើ
ស៊ីថន
ឈ្នះ
កីឡាករថៃ ។
.ប្រ
ក.ន
ឃ.រណប
(ឃ២)
កិ
ន

### ៣.ល្បះផ្សំ-ក្រង(Compound-comple



## ៤.ល្បះក្រុង(Compound Sentence)




**អក្សរកាត់ដែលប្រើនៅក្នុងសៀវភៅនេះ**

នាម (ន)
កិរិយាសព្ទ (កិ)
គុណនាម (គុ)
គុណកិរិយា (គុ. កិ)
ឈ្នាប់ (ឈ)
ធ្នាក់ (ធ)
ល្បះ (ល)

កន្សោមនាម (ក. ន)
កន្សោមកិរិយា (ក. កិ)
កន្សោមនាមប្រធាន (ក. នប្រ)
កន្សោមមានធ្នាក់ (កមធ)
នាមប្រធាន (ន. ប្រ)
សព្វនាមប្រធាន (សព្. ប្រ)

៦៦-III-៩៧



CATALOGED IN NGL
No: 2349
Date: 25/07/2012

35



ខ្ញុំបាទ **ឆន ឈាង** កើតនៅថ្ងៃទី២៧ កុម្ភៈ ១៩៦៤

ឪពុកឈ្មោះ **ហ៊ិន ឆន** ម្ដាយឈ្មោះ **ម៉ោក សុខ**

នៅភូមិកន្លោង ឃុំទឹកថ្លា ស្រុកព្រៃវែង ខេត្តព្រៃវែង។

ក. ប្រវត្តិការសិក្សា:

ពីកុមារភាព ដល់ ១៩៧៥ រៀននៅសាលាក្នុងភូមិកន្លោងនិងវត្តព្រៃល្វា

១៩៧៥ ដល់ ៧៩ មិនបានរៀនទេ(សម័យ ប៉ុល ពត)

១៩៧៩ ដល់ ៨១ រៀននៅសាលាកំរិតសិក្សាទី១ វត្តទឹកថ្លា (វិញ្ញាបនប័ត្រ)

១៩៨១ ដល់ ៨៤ រៀននៅសាលាកំរិតសិក្សាទី២ ព្រៃវែងក្រុង (សញ្ញាប័ត្រកំរិតសិក្សាទី២)

១៩៨៤ ដល់ ៨៦ រៀននៅសាលាគរុកោសល្យ ភូមិភាគព្រៃវែង

១៩៨៨ ដល់ ៩២ រៀននៅសាកលវិទ្យាល័យភ្នំពេញ (សញ្ញាប័ត្រថ្នាក់ឧត្ដមសិក្សា)

ខ. ប្រវត្តិការងារ:

១៩៨៦ ដល់ ៨៨ គ្រូបង្រៀនអក្សរសាស្ត្រខ្មែរនៅវិ. ស្វាយអន្ទរ ព.វ

១៩៩២ ដល់ ៩៥ គ្រូបង្រៀនអក្សរសាស្ត្រខ្មែរនៅវិ. ព្រះស៊ីសុវត្ថិ ភ.ព

១៩៩៥ ដល់ ៩៧ អ្នកនិពន្ធសៀវភៅសិក្សាភាសាខ្មែរ នៃក្រសួងអប់រំ

១៩៩៧ ដល់ បច្ចុប្បន្ននេះ(២០០២)ជាអ្នករៀបរៀង នៃគ្រឹះស្ថានបោះពុម្ព

និងចែកផ្សាយ ក្រសួងអប់រំ យុវជន និងកីឡា។

*ទូរស័ព្ទទាក់ទងលេខ* (០១២) ៩៤៤ ៤៧៣


**មានលក់ដុំ និង លក់រាយ**

- នៅផ្សារអូរឫស្សី តូបលេខ: ២៣ / ៣៤
- នៅបណ្ណាគារអង្គរធំ(ខាងកើតផ្សារធំថ្មី ប្រវែង២០០ម៉ែត្រ)
  ទូរស័ព្ទលេខ: (០២៣) ២១០ ២៥៨ / (០១១) ៤២៨ ៤៩៩
- ក៏មានលក់ផងដែរ នៅកន្លែងផ្សេងៗទៀត។

មូលនិធិខ្មែរសម្រាប់ការសិក្សា    ករុណាខ្មែរ